BMI00143

# សម្ភាសន៍ជាមួយ ឡូត បណ្ដែត ភេទស្រី អាយុ៥៥ឆ្នាំ
# មុខងារសម័យខ្មែរក្រហមៈ មេកងចល័តទំនប់ត្រពាំងថ្ម
# រស់នៅភូមិជើងវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# សម្ភាសន៍ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

០១:០៦:៤១

៣២ទំព័រ

ដារ៉ា : ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីងពេញសិន មីងឈ្មោះអីដែរ?

បណ្ដែត : ឡូត បណ្ដែត ។

ដារ៉ា : ឡូត បណ្ដែត?

បណ្ដែត : ចា៎!

ដារ៉ា : មីងឈ្មោះហ្នឹង អត់មានឈ្មោះប្រែអីទេ?

បណ្ដែត : ឈ្មោះពីរតូចមក ម៉ែពេលដែលយំច្រើនពេក ក៏ហៅឈ្មោះពីរ ឈ្មោះមួយតៀ ឈ្មោះមួយឈ្មោះដែត ឡូត តៀ, ឡូត បណ្ដែត ។

ដារ៉ា : ឥឡូវមីងប្រើតែឈ្មោះ ឡូត បណ្ដែត ទេ?

បណ្ដែត : ចា៎!

ដារ៉ា : មីងសព្វថ្ងៃអាយុប៉ុន្មានឆ្នាំហើយមីង?

បណ្ដែត : ៥៥ ហើយអូន ។

ដារ៉ា : ស្រុកកំណើតមីងនៅណាដែរ?

បណ្ដែត : នៅនេះឯង ។

ដារ៉ា : ភូមិអីគេ?

បណ្ដែត : ភូមិជើងវត្ត ។

ដារ៉ា : ឃុំ?

បណ្ដែត : ឃុំព្រះនេត្រព្រះ ។

ដារ៉ា : ស្រុក?

បណ្ដែត : ស្រុកព្រះនេត្រព្រះ ។

ដារ៉ា ៖ ខេត្តបន្ទាយមានជ័យ?

បណ្ឌិត ៖ ខេត្តបន្ទាយមានជ័យ ។

ដារ៉ា ៖ ហើយសព្វថ្ងៃរស់នៅភូមិហ្នឹងដែរ?

បណ្ឌិត ៖ នៅភូមិដដែរ ។

ដារ៉ា ៖ មីងមានបងប្អូនប៉ុន្មាននាក់?

បណ្ឌិត ៖ ៤នាក់ ។

ដារ៉ា ៖ ឈ្មោះអីខ្លះ?

បណ្ឌិត ៖ ឈ្មោះ ឡូត ស៊ីត្ថា ។

ដារ៉ា ៖ ឡូត អីទៀត?

បណ្ឌិត ៖ ឡូត សួយ, ឡូត សៀ ។ ប្រុស២ ស្រី២ ។

ដារ៉ា ៖ ប្រុស២ ស្រី២?

បណ្ឌិត ៖ ចាំ! ខ្ញុំជាកូនទី២ បងស្រីខ្ញុំនោះ ។

ដារ៉ា ៖ ហើយឪពុកមីងឈ្មោះអីដែរ?

បណ្ឌិត ៖ ឈ្មោះ ឡូត ណុ ។

ដារ៉ា ៖ ឡូត អី? ឡូត អន្ទក់?

បណ្ឌិត ៖ ឡូត ណុ ។

ដារ៉ា ៖ ឡូត ណុ?

បណ្ឌិត ៖ ណុ ។

ដារ៉ា ៖ គាត់នៅរស់ដែរ?

បណ្ឌិត ៖ នោះគាត់ ផ្ទះពុកខ្ញុំ ពុកខ្ញុំ ម៉ែខ្ញុំ នៅទាំងអស់ ។

ដារ៉ា ៖ អីចឹងគេកំពុងសម្ភាសន៍ហ្នឹង សម្ភាសន៍របស់ឪពុកមីងហើយ?

បណ្ឌិត ៖ ចាំ! ពុកខ្ញុំ ។

ដារ៉ា ៖ ហើយម្ដាយមីង?

បណ្ឌិត ៖ ម្ដាយខ្ញុំ ឈ្មោះ ប៉ាក ខួន ។

ដារ៉ា ៖ ប៉ាក ខួន?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ ហើយមីងមានគ្រួសារនៅ?

បណ្ឌិត ៖ នោះប្ដីខ្ញុំ ។

ដារ៉ា ៖ ហើយត្រកូលសាររមីងឈ្មោះអី?

បណ្ឌិត ៖ គុយ ខឿង ។

ដារ៉ា ៖ គុយ ខឿង?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ គាត់អាយុប៉ុន្មានឆ្នាំហើយ?

បណ្ឌិត ៖ ៥៦ឆ្នាំ ។

ដារ៉ា ៖ គាត់អ្នកស្រុក អ្នកភូមិ ជាមួយមីងដែរ?

បណ្ឌិត ៖ អ្នកភូមិជាមួយគ្នា ។

ដារ៉ា ៖ ហើយមីងមានកូនចៅប៉ុន្មាននាក់?

បណ្ឌិត ៖ កូន៤ ។

ដារ៉ា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

បណ្ឌិត ៖ ប្រុស៣ ស្រី១ ។

ដារ៉ា ៖ ហើយមីងរាល់ថ្ងៃរបរអីដែរ?

បណ្ឌិត ៖ របរតិចតួច លក់ដូរខោអាវតិចតួច ។

ដារ៉ា ៖ មានធ្វើស្រែ ធ្វើចម្ការដែរ?

បណ្ឌិត ៖ ធ្វើដែរ ធ្វើដំរុំ ។

ដារ៉ា ៖ អីចឹងបានន័យថា យើងធ្វើស្រែ ចម្ការ រួមផ្សំជាមួយការលក់ដូរ ។

បណ្ឌិត ៖ ចាំ! ឆ្នាំមុនខាងច្រើន ខាតអស់ជិត៣លាន រកស៊ីអស់ ។

ដារ៉ា ៖ ហើយពីមុនមីងមានបានទៅរៀនសូត្រ ទៅសាលារៀនដែរ?

បណ្ឌិត ៖ ខ្ញុំរៀន រៀនសម័យ លន់ នល់ ។

ដារ៉ា ៖ ដល់ថ្នាក់ទីប៉ុន្មានមីង?

បណ្ឌិត ៖ ថ្នាក់ទី៨ ។

ដារ៉ា ៖ អីចឹងអត់ទាន់បានទៅប្រឡងនឹងគេទេ?

បណ្ឌិត ៖ មិនបានប្រឡងទេ វាចប់ទៅ វាបរិវិទៅ មិនបានរៀនទៀតទេ សម័យនោះ រៀនសាលា
រៀននៅនេះឯង អត់បានរៀនដល់ស្វាយទេ ។

ដារ៉ា ៖ សាលាអីគេ?

បណ្ឌិត ៖ សាលាព្រះនេត្រព្រះនេះឯង សាលាព្រះនេត្រព្រះមានថ្នាក់ទី៧, ទី៨, ប៉ុណ្ណោះឯង ទី៦ រៀននៅស្វាយ ។

ដារ៉ា ៖ អីចឹងមានត្រឹមតែថ្នាក់ទី៧ទេ?

បណ្ឌិត ៖ ចា៎! ទី៧, ទី៨ ប៉ុណ្ណឹងឯង បើចប់ទី៧យើងបានទៅរៀនស្វាយ សម័យនោះ ។

ដារ៉ា ៖ ហើយមីងបានរៀនត្រឹមថ្នាក់ទី៨ទេអីចឹង?

បណ្ឌិត ៖ ចា៎!

ដារ៉ា ៖ រៀនហើយម៉េចបាន?

បណ្ឌិត ៖ សម័យអាពត ។

ដារ៉ា ៖ អាពតចូលមកដល់តែម្តង?

បណ្ឌិត ៖ ចា៎! ចូលមកដល់ក៏ឈប់ទៅ មិនបានរៀនសូត្រអីទេ ។

ដារ៉ា ៖ អីចឹងឈប់ហ្នឹងចំពេលដែលសម័យប៉ុល ពត ចូលមកដល់ម្មង?

បណ្ឌិត ៖ វាបរិវិមុនហ្នឹង ជិតកន្លះឆ្នាំ គ្មានបានរៀនទេ វារវល់តែវល់វិ វារ៉ៃនេះ រ៉ៃនោះ មានបាន ជួលគ្រូឯណាបានបង្ហាត់យើង រត់ដូចតែគ្នា គ្មានអ្នកណា បានបង្ហាត់អ្នកណាទេ សិស្សប្រុង គ្រូប្រុងរៀងតែខ្លួន គ្មានបានរៀនទេ ផ្អើល ស្រុកនេះផ្អើលក្រោយគេ ព្រះនេត្រព្រះរ៉ែឯណាចប់ហើយ មកចប់ព្រះនេត្រព្រះនេះឯង រ៉ៃក្រោយគេបង្អស់ ចប់ទៅ បាញ់គ្នាស្រែះអីទៅ បាញ់គ្នាទៅ សម័យ លន់ នល់ បាញ់គ្នា ផ្ទោងមកគ្រាប់ជះមក ។

ដារ៉ា ៖ ពេលដែលរបបប៉ុលពត ចូលមកដល់ភ្លាមតែម្តង មីងនៅក្នុងភូមិហ្នឹងទេ ឬម៉េច?

បណ្ឌិត ៖ អត់ទេ ជម្លៀស ឲ្យរែកទៅភ្នំកូនដំរី ហើយបានទៅត្រពាំងនោះ ។

ដារ៉ា ៖ ជម្លៀសហ្នឹងជម្លៀសអ្នកភូមិទូទៅតែម្តង ឬក៏?

បណ្ឌិត ៖ ជម្លៀសដូរភូមិគ្នា ។

ដារ៉ា ៖ អីចឹងដូរភូមិគ្នា ។

បណ្ឌិត ៖ ខ្ញុំក៏ទៅនៅភូមិគេ គេមកនៅភូមិខ្ញុំទៅ ។

ដារ៉ា ៖ អ្នកស្រុក ។

បណ្ឌិត ៖ ពីឆ្ងាយមក វល់វិលាយគ្នាទៅ ។

ដារ៉ា ៖ ភូមិដើងវត្តនេះ ដូរទៅនៅភូមិណា?

បណ្ឌិត ៖ ទៅភូមិតាបែន ។ ភូមិតាបែនក៏ទៅនៅឯណាផ្សេងទៀតទៅ ដូរគ្នា ដូយត្តឹងក៏ទៅស្នឹកគ្រែអីទៅ វាដូរគ្នាវល់វិ វាមិនបានឲ្យនៅឯងវិញទេ ខ្ញុំទៅនៅតាបែន ។

ដារ៉ា ៖ ត្រពាំងអីគេ?

បណ្ឌិត ៖ ភូមិតាបែន ស្រុកទ្រាំងស្ដុប ។

ដារ៉ា ៖ ស្ដុបអីគេ?

បណ្ឌិត ៖ ស្ដុប ព្រៃឈើ ។

ដារ៉ា ៖ ព្រៃស្ដុប?

បណ្ឌិត ៖ ចា៎!

ដារ៉ា ៖ សុទ្ធតែព្រៃ?

បណ្ឌិត ៖ ចា៎! វាមិនស្អាតស្រឡះទេ ពួកខ្ញុំទៅនៅ នាំគ្នាកាប់ឆ្ការទៅក៏ស្អាត ហោសដ្រះទៅក៏ស្អាត ចូលទៅមុនដំបូងនោះមិនហ៊ានទេ ថាខ្លាច ស្ដុបណាស់ ព្រៃដុំអីចេះឯង ពួកខ្ញុំទៅ នៅក៏ឆ្ការឲ្យ ស្រឡះ ។

ដារ៉ា ៖ ពេលទៅនៅតាបែនអ្នកណាជាប្រធានភូមិកាលហ្នឹង?

បណ្ឌិត ៖ ប្រធានភូមិនិរតី ភាគីរំដោះចាស់ ឈ្មោះ តាអីម៉ែម៉ុំ ដែលប្រធានភូមិយើងឈ្មោះអីភ្លេច ឈ្មោះគាត់ ។

អ្នកជិតខាង៖ ប្រធានភូមិ តាហិន ។

បណ្ឌិត ៖ តាហិន អ្នករំដោះចាស់ គេអត់មានឲ្យយើងអ្នក ១៧មេសា ធ្វើមេភូមិ មេអីទេ ។

ដារ៉ា ៖ តាហិន ហ្នឹងគាត់នៅរស់ដល់សព្វថ្ងៃដែរ?

បណ្ឌិត ៖ ស្លាប់ហើយ ។

ដារ៉ា ៖ ហើយកាលហ្នឹងមីងអាយុប៉ុន្មានឆ្នាំ ពេលដែលជម្លៀសហ្នឹង?

បណ្ឌិត ៖ ជម្លៀស១៩ហើយ ។

ដារ៉ា ៖ ១៩ហ្នឹង មីង?

បណ្ឌិត ៖ ជម្លៀសចេញទៅចល័តហើយ ។

ដារ៉ា ៖ ទៅកងចល័ត?

បណ្ឌិត ៖ ទៅកងចល័តហ្នឹងលើកអានេះរួច នេះលើកអាខាងទំនប់រន្ទះបាញ់រួច បានគេបញ្ជូនទៅកន្លែងត្រពាំងថ្ម លើកទំនប់នេះឡើងរួច ។

ដារ៉ា ៖ ទំនប់រន្ទះបាញ់ហ្នឹង?

បណ្ឌិត ៖ ចា៎!

ដារ៉ា ៖ ស្ថានភាពលើកកន្លែងហ្នឹងម៉េចទៅមីង ជួយរៀបរាប់?

បណ្ឌិត ៖ លើកម្នាក់៣ម៉ែត្រគីប ទាំងអស់គ្នាទៅ ប្រុស៣ម៉ែត្រគីប ស្រី៣ម៉ែត្រគីប បើមិនរួចក៏មិនបានបាយស៊ី ដល់ខំទាល់តែរួច ។

ដារ៉ា ៖ ចុះការចុះទៅធ្វើការងារពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មាន?

បណ្ឌិត ៖ ម៉ោង៥ ។

ដារ៉ា ៖ ៥ទៀបភ្លឺយើងហ្នឹង?

បណ្ឌិត ៖ ទេ ៥ព្រឹកភ្លឺ ដល់ចូលវិញក៏៥ដែរ ចាប់ធ្វើពីម៉ោង៥ដល់ម៉ោង៩ឈប់ទៅដេក ក្រោកភ្លឺម៉ោង៥ ក្រោកធ្វើម្តងទៀត ។

ដារ៉ា ៖ ហើយការហូបចុកយ៉ាងម៉េចវិញ?

បណ្ឌិត ៖ ហូបចុកមុនដំបូងមិនសូវខ្វះទេ ដល់ទៅលើកស្ពាននោះ ។ អានេះទើបតែថ្មីៗយើងលើកនេះទើបតែរំដោះថ្មីៗ ទៅលើកមិនសូវជាខ្វះខាតប៉ុន្មានទេ អ្នកលើកទំនប់មិនសូវអត់ទេ ព្រោះគេបញ្ជូនថាសមរភូមិមុខ ពាក្យថាសមរភូមិមុខសម័យនោះគេឲ្យហូបឆ្អែត តែយើងធ្វើការឲ្យគេទាល់តែបាន បើមិនបានអត់បានបាយហូបទេ ។

ដារ៉ា ៖ ៣ម៉ែត្រគីបហ្នឹងចង់និយាយថាកំលាំងស្រួចហើយមីង? បើនិយាយទៅ ។

បណ្ឌិត ៖ គេហៅទ័ពស្រួចហើយ ទាល់តែខំទៅណា៎ ក្នុងថ្ងៃ បើយើងថាក្រោកពីម៉ោង៥ទៅដល់ម៉ោង១១យើងបាន១ម៉ែត្រគីបកន្លះ សំរាកសិន ចាប់ពីម៉ោង១១ទៅទៀតយើងលើកទៅដល់ល្ងាចរួច ។

ដារ៉ា ៖ អ៊ីចឹងចន្លោះថ្ងៃអត់មានហូបបាយទេអ៊ីចឹង?

បណ្ឌិត ៖ ហូបម៉ោង១១ បាយ បន្ទាប់ពីសំរាកចាប់ពីម៉ោង១ហ្នឹងរែកទៅទៀត ប៉ះដីរឹងមិនរួចទេអត់រួចទេ ដីក្រួស ។

ដារ៉ា ៖ អ៊ីចឹងមីងភាគច្រើនប៉ះចំដីអី?

បណ្ឌិត ៖ ដីដូចថា ចបមួយចំហៀងក៏មុតទៅ អ្នកខ្លះធ្វើប៉ះដីក្រួស រាងខ្មៅៗកាប់មិនមុត ឡើងព្រាយ មកវិញ គាំភ្លើងៗមក ។

ដារ៉ា ៖ ហើយពេលនោកងចល័តលើកទំនប់ គេហៅទំនប់មេម៉ាយ?

បណ្ឌិត ៖ ស្ពានមេម៉ាយ ។

ដារ៉ា ៖ លើកស្ពានមេម៉ាយ មេកងមីងឈ្មោះអី?

បណ្ឌិត ៖ មេកងខ្ញុំ ខ្ញុំហ្នឹងហើយប្រធានកង ។

ដារ៉ា ៖ មីងមេកង?

បណ្ដែត : ចា៎!

ដារ៉ា : មីងគ្រប់គ្រងគ្នាប៉ុន្មាននាក់?

បណ្ដែត : ១០០នាក់។

ដារ៉ា : ច្រើន?

បណ្ដែត : មួយកង ១០០។

ដារ៉ា : ហើយមីងមេកងគេ?

បណ្ដែត : ចា៎! វែកដី ខ្លះមិនពេញថាពេញទៅ កុហក។

ដារ៉ា : អីចឹង?

បណ្ដែត : បើមិនកុហកទេ គ្នាម៉េចរួច សម័យនោះបើមិនឆ្លាតអត់ បើថានេះពូងងវែកអត់រួចទៅណា៎ វែកទៅបានមួយម៉ែត្រគីបកន្លះទេ ប៉ុន្ដែសួរខ្ញុំក្នុងបញ្ជីខ្ញុំចុះស្រេច៣ម៉ែត្ររួចហើយ រួចហើយឡើងមកគេឲ្យបាយស៊ីហើយ បើយើងមិនថាអីចឹងគ្មានអ្នកណាវែករួចទេក្នុង៣ម៉ែត្រគីប បើថ្ងៃណាគ្នាវែករួចក៏យើងចុះតាមដំណើរទៅ ឲ្យបានហូបទាំងអស់គ្នា ចាប់ផ្ដើមធ្វើទៀតទៅ។ បើកំលាំងប្រុសលើករួច បើកំលាំងស្រីបានតែម៉ែត្រគីបកន្លះទេ យើងប្រធានក៏យើងវែកដែរ កុំថាយើងប្រធានកងមិនវែកណា៎ យើងវែក បើកាលណារួចហើយគ្នាយើងក៏ជួយគ្នាទៅ បើជួយមិនរួចទេក៏យើងលែលកគ្នាទៅ កត់ទៅ ទាល់តែយើងឆ្លាតបន្ដិច បើមិនឆ្លាត គឺមិនរស់ យើងថាបានមួយម៉ែត្រគីបកន្លះ បើខ្ញុំប្រធានកងបាន៣ម៉ែត្រគីបហើយឈ្មោះនេះ សរសេរជាឈ្មោះដាក់ទៅក្នុងថ្ងៃនេះ ប៉ុន្ដែមិនបានទេ បើមិនលាក់ឲ្យគ្នាគ្នាមុខតែអត់ហើយ ខ្លះបាន ខ្លះអត់បានទេក្នុងមួយកង ខ្លះរួច ខ្លះអត់រួច។

ដារ៉ា : ហើយមីងម៉េចបានធ្វើជាប្រធានកងគេ?

បណ្ដែត : ស្រេចគេ គេរើស គេមើលទៅយើង គេមើលថាយើងសន្ទំសំនួនទៅ មើលទៅអាចចេះអាចដឹង ប៉ុន្ដែសម័យនោះមើលស្គាល់ថាអ្នកចេះ អ្នកមិនចេះ។

ដារ៉ា : មើលស្គាល់ម៉េច?

បណ្ដែត : មើលស្គាល់ថាយើងចេះអក្សរ មិនចេះ វាស្គាល់។

ដារ៉ា : មើលដឹងតែម្ដង?

បណ្ដែត : ស្គាល់ បើយើងចេះអក្សរខ្លះអីទៅ អ្នក១៧ បើអ្នករំដោះចាស់មិនសូវចេះទេ ច្រើនតែអ្នកធ្វើពេទ្យធ្វើអីនោះមិនសូវចេះទេ យើងអ្នក១៧មេសា ចេះច្រើនណាស់ ហើយច្រើនតែផាប់អ្នក១៧មេសា ភាគច្រើន ព្រោះយើងអ្នកចេះច្រើន។

ដារ៉ា ៖ ហើយមីងជាប្រធានកងអីចឹង អ្នកណាជាអ្នកចាត់ចែងមីង?

បណ្ឌិត ៖ តាវ៉ាល់ ។

ដារ៉ា ៖ ឈ្មោះតាវ៉ាល់?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ តាវ៉ាល់ ហ្នឹងគាត់ឋានៈស្អី?

បណ្ឌិត ៖ ឋានៈធំ ក្តាប់មួយតំបន់ ហៅឋានៈមួយតំបន់ ដូចថានេះមួយតំបន់ ហៅកងចល័ត៤ស្រុក

ដារ៉ា ៖ ក្នុងមួយតំបន់ហ្នឹងមាន៤ស្រុក?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ ស្រុកអីខ្លះ?

បណ្ឌិត ៖ ស្រុកព្រះនេត្រព្រះ, ស្រុកសិរីសោភណ្ឌ, ស្រុកថ្មពួក, ស្រុកភ្នំស្រុក ៤ស្រុក ទទួល៤ស្រុក ។

ដារ៉ា ៖ គាត់ជាប្រធានតំបន់?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ ឈ្មោះ តាវ៉ាល់?

បណ្ឌិត ៖ ចាំ!

ដារ៉ា ៖ ពេលមកចាប់តាំងមីងជាប្រធានកង តាវ៉ាល់ ហ្នឹងតែម្តង?

បណ្ឌិត ៖ ចាំ! តាវ៉ាល់ គាត់ចាត់ចែងរួចបានបែកឃ្លាពីទំនប់នេះ បានខ្ញុំទៅទំនប់ត្រពាំងថ្ម ។ ត្រពាំងថ្មវាលស្រែទទេគ្មានស្អីទេ ។

ដារ៉ា ៖ ពេលចាត់តាំងមីងជាប្រធានកងហ្នឹង ពេលមីងត្រូវរាយការណ៍ៗ ទៅអ្នកណា?

បណ្ឌិត ៖ រាយការណ៍ទៅគាត់ ដូចថាមានវរៈគេមួយទៀត ប្រធានវរៈគេក្តាប់ក្នុង៣០០នាក់ យើងដូចជាវងរបស់គេទៅ ផ្ញើបញ្ជីវត្តនាមយើងឡើងទៅប្រធានវរៈ ប្រធានវរៈឡើងទៅរកគាត់ ប្រធានវរៈក្តាប់៣០០ ។

ដារ៉ា ៖ ប្រធានវរៈក្តាប់៣០០ មានន័យថា៣កង?

បណ្ឌិត ៖ ចាំ! ៣ក្នុងប្រធានវរៈ ។

ដារ៉ា ៖ ហើយប្រធានវរៈរបស់មីងឈ្មោះអីដែរ?

បណ្ឌិត ៖ បង ភ្លេចឈ្មោះគាត់បាត់ហើយ នៅវុញ្ញ ជ្រែងសព្វថ្ងៃ ។

ដារ៉ា ៖ ដូនជ្រែញ ។ គាត់នៅរស់ដែរ?

បណ្ដិត ៖ មិនដឹងទេ បើខ្ញុំមិនដែលបានទៅ។ បងម៉ៅ, បងវឿន ប្រធានវរៈ ស្រីណា៎ មិនមែនប្រុសទេ។

ដារ៉ា ៖ ឈ្មោះម៉ៅ, ឈ្មោះ វឿន?

បណ្ដិត ៖ ចា៎! បងវឿន។

ដារ៉ា ៖ វឿន ហ្នឹងស្រី ឬប្រុស?

បណ្ដិត ៖ ស្រី ខ្វាចតែងាប់ដងមិនដឹង នៅឆ្ងាយគ្នាមិនដែលបានទៅ ខ្ញុំមិនដែលបានទៅ។

ដារ៉ា ៖ នៅក្នុងកងមីងដែលថា១០០នាក់ហ្នឹង មានអ្នកខ្លះស្លាប់ ឬឈឺ ឬក៏អីដែរ?

បណ្ដិត ៖ មិនសូវឈឺទេ មុនដំបូងអីចឹងសំបូរ អត់សូវមានឈឺ បើទៅខាងត្រពាំងថ្មបានឈឺចាប់ផ្ដើមស្គមស្គាំង។

ដារ៉ា ៖ ដំបូងមីងចង់និយាយក្នុងរយៈពេលឆ្នាំណាដែរ?

បណ្ដិត ៖ មិនដឹងជិតប៉ុន្មាន មិនបានចាំផង ត្រពាំងថ្ម។

ដារ៉ា ៖ អត់ទេ កាលដំបូងនៅស្ពានមេម៉ាយ?

បណ្ដិត ៖ ឆ្នាំ៧៨ រំដោះភ្លាមទៅគេឲ្យទៅលើកស្ពានមេម៉ាយហ្នឹង ខ្ញុំមិនសូវគិតគូរវឿងឆ្នាំ។ ធ្វើចេះតែធ្វើទៅ។

ដារ៉ា ៖ នៅហ្នឹងបានយូរទេ?

បណ្ដិត ៖ មួយរួចទំនប់?

ដារ៉ា ៖ រយៈពេលប៉ុន្មានខែ ឬប៉ុន្មានឆ្នាំ?

បណ្ដិត ៖ ជិតមួយឆ្នាំដែរ ស្ពានមេម៉ាយវាវែង ហើយកំពស់វាខ្ពស់ដែរ។

ដារ៉ា ៖ កំពស់ប៉ុន្មាន?

បណ្ដិត ៖ កាលនោះបាតទំនប់វា១៥ កំពស់៥ ហើយខ្នងវាក៏៥ម៉ែត្រ តែសព្វថ្ងៃរាបទាបអស់ហើយ កាលថ្មីវិញវាខ្ពស់បាតទំនប់។

ដារ៉ា ៖ លើកអាហ្នឹងហើយបានបន្តទៅលើកត្រពាំងថ្ម?

បណ្ដិត ៖ ស្ពានមេម៉ាយរួច ស្ពានស្រែន។

ដារ៉ា ៖ ចប់ពីស្ពានមេម៉ាយទៅ ស្ពានស្រែន?

បណ្ដិត ៖ ទេ ត្រពាំងថ្ម។ ពីនេះរួចបានទៅលើកត្រពាំងថ្ម ចប់អានេះរួច បានទៅត្រពាំងថ្មស្ពានទី១ មុខទឹកលើកអានោះឯង ចំនួនគ្នាច្រើនណាស់ ៤ស្រុក វៃលើកអានោះឯងលើកនឹង កំលាំង គ្មានស្អីទេ វែកឡើងទាំងខ្វាក់មាន់ ពួកខ្ញុំសុទ្ធតែខ្វាក់មាន់ វែកឡើង

ចាប់ធ្វើមុន ដំបូងសុទ្ធតែវាលស្រែ គ្មានស្ទើទេ អាងត្រពាំងថ្មគ្មានក្រឡុកមានអីទេ ស្រែរាបរយ រាប់ពាន់ហិចតា ឡើងវាលស្រឡះល្វឹង ចាប់វាស់១៥ម៉ែត្រ កំពស់៥ ខ្នងលើ៥ម៉ែត្រ ដីហ្នឹង ។

ដារ៉ា ៖ ចេញស្តង់ដារអីចឹងតែម្តងមីង ម៉េច?

បណ្ឌិត ៖ គេវាស់ប្រុសៗឆាយលើខ្នងទំនប់មួយស្អាតទៅ ស្រីៗក៏វែកទៅ ស្រី-ប្រុសទាំងអស់គ្នា ចាប់កងតាមកងប្រុសៗតាមកងស្រី ផ្សេងៗគ្នា លើកទៅ ។

ប្រុញៈ សុំកាត់អ្នកមីងពេលដែលខ្មែរក្រហមចូលភ្លាម ជម្លៀសទៅខាងស្ពានមេម៉ាយហ្នឹងធ្វើភ្លាម?

បណ្ឌិត ៖ ចាប់ផ្តើមធ្វើ ។

ប្រុញ ៖ មានន័យគ្រាន់តែចូលភ្លាម ជម្លៀសទៅភ្លាម?

បណ្ឌិត ៖ ទេ រៀបភូមិក្នុង៤-៥ខែរវល់រៀបទីជំរកពិតប្រាកដ ដល់រួចចាប់ផ្តើមជម្លៀសក្រមុំកំលោះឲ្យទៅលើកទំនប់ទៅអស់ ។

ប្រុញ ៖ ទៅបានប៉ុន្មានខែ បានទៅនោះ?

បណ្ឌិត ៖ ធ្វើនោះរួចបានទៅនោះស្ពានត្រពាំងថ្ម ធ្វើនោះឯង ។

ប្រុញ ៖ នៅនោះប្រហែលប៉ុន្មានខែ នៅកន្លែងស្ពានមេម៉ាយ?

បណ្ឌិត ៖ ប្រហែល៥ខែ ៦ខែ បានរួច មិនឆាយទេណា៎ ទំនប់រឹងកំលាំងឡើងចុកដល់ដំបូល ពីស្រែដល់ដំបូល ។

ប្រុញ ៖ អីចឹងអ្នកមីងអាចស្មានថាពេលដែលទៅត្រពាំងថ្ម ប្រហែលជាដើមឆ្នាំ៧៦ ឬយ៉ាំងម៉េច?

បណ្ឌិត ៖ ៧៦, ៧៧ហើយ ព្រោះនៅលើកឲ្យរួច អានោះទៅត្រពាំងថ្មមកវិញ ស្រាប់តែខ្ញុំមកនៅស្រុកបានជិត៥ខែ គេបរិវិសន្តិភាព ខ្ញុំត្រឡប់មកវិញគេលើកដី ។

ដារ៉ា ៖ ទៅលើកនៅត្រពាំងថ្ម ច្រើនខែ ច្រើនឆ្នាំដែរ?

បណ្ឌិត ៖ យូ ចង់មួយឆ្នាំជាងទំនប់ហ្នឹង ទំនប់ហ្នឹងលើកយូរណាស់ ។

ដារ៉ា ៖ មីងទៅត្រពាំងថ្មហ្នឹងទៅមួយកងមីងហ្នឹងម្តង ឬយ៉ាំងម៉េច?

បណ្ឌិត ៖ មួយកង ខ្លះក៏បែក ទៅដល់នោះបែកគ្នា បែកគ្នាលើកដីរួចបាននៅជុំគ្នា ប្រមូលមកដាក់ត្រពាំងថ្មសំរុកឲ្យរួច ទៅដល់ប្រធានកងខាងយុវជន គេវាស់ដី ខាងអ្នកឆាយដីខ្នងទំនប់ គេចាប់វាស់ដីឲ្យយើង ដូចថាក្នុងវរៈយើងនេះចំនួន៣០០នាក់ នៅកន្លែងមុខនេះឯង ។

ដារ៉ា ៖ មុខគេ?

បណ្ដែត ៈ មុខគេ ស្ពានទី១ហ្នឹងមុខគេ លើកមុខគេទៅ មុខហ្នឹងមានចំនួន៣០០នាក់នោះ ប្រុសផង ស្រីផង ចំរុះគ្នា លើកតាមមុខយើងដែលគេវាស់ឲ្យមួយខ្សែ១០០ម៉ែត្រ ហើយគេក៏តពីយើង១០០ម៉ែត្រទៅទៀតទៅ តឡើងអស់ដល់ស្ពានទី៣ រៀងៗខ្លួន ហើយបើកំពស់ទំនប់គេវាស់ឲ្យយើងស្រេច ចាក់ទៅដល់១៥ម៉ែត្រ ចាក់ឲ្យដល់ជើងវា បេះតែរែកចាក់ៗទៅទាំងអស់គ្នា រែកចាក់រហូតដល់ទំនប់ហ្នឹងកំពស់បាន៥ម៉ែត្រកំពស់ ប្រុសៗនៅលើខ្នងទំនប់ឆាយ ឆាយខ្នងទំនប់លើ៥ម៉ែត្រ ដាក់ឲ្យស្រឡះទៅ ។

ដារ៉ា ៈ អាដីនៅត្រពាំងថ្មរឹង?

បណ្ដែត ៈ រឹងចំណាប់ សុទ្ធតែដីក្រួស លើកមួយថ្ងៃៗមិនចង់បាន២ម៉ែត្រគីបទេ កាប់ទៅសុទ្ធតែដីក្រួស វាផុយតែលើចំនួនមួយម៉ែត្រ ចាប់ទៅក្រោមដីរឹងហើយ ដីខាងក្រោមសុទ្ធតែដីក្រួស ។

ប្រុញ ៈ មីងមានដឹងថានៅទីហ្នឹងប្រហែលជាមានប៉ុន្មានកងទេ ដែលលើកនៅត្រពាំងថ្ម?

បណ្ដែត ៈ ច្រើនណាស់រាប់មិនអស់ទេ ។

ប្រុញ ៈ ជាទូទៅមួយកងមានប៉ុន្មាននាក់ដែរ?

បណ្ដែត ៈ មួយកង១០០ៗ ច្រើនវរៈណាស់ ដាក់ពីនេះទៅនោះមនុស្សឡើងសក្បុស តែចូលដល់ស្ពានទី៣ ។

ប្រុញ ៈ ចុះកងខ្លះគេថា៣០អីដែរ ហ្នឹងម៉េចដែរ?

បណ្ដែត ៈ ហ្នឹងកង៣០ក៏មាន កង១០០ក៏មាន កងស្រួច កងបង្ខំឲ្យលឿនក៏មាន១០០ទៅមានតាម ហ្នឹង កងឆាយដីមាន៣០នាក់ទៅ អាខ្នងទំនប់សំរាប់អ្នកឆាយដីវាកំពស់វៀចខ្នងទំនប់ធ្វើឲ្យ ស្អាតវាមានកងគេផ្សេងទៅ គេរៀបចំរបស់គេផ្សេង ។

ប្រុញ ៈ បើអ្នកមីងស្មានប្រហែលជាមានប៉ុន្មានកងឡើងទៅ?

បណ្ដែត ៈ ច្រើនរាប់មិនអស់ទេ ខ្ញុំនៅតែត្រៀមខាងមុខនោះឯង នៅស្ពានទី១ ។

ដារ៉ា ៈ ពេលដែលទៅដល់ត្រពាំងថ្មហ្នឹង ការចុះធ្វើការងារម៉េចដែលមីង? ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

បណ្ដែត ៈ ធ្វើដូចតែគ្នាអីចឹង ចាប់ពីម៉ោង៥ដល់ល្ងាច ចាប់ពីម៉ោង៥ទៅដល់ម៉ោង៩យប់ យើងចង់ឲ្យលឿនទៅឲ្យរួចលឿន យើងខំដល់ម៉ោង១០ក៏ចុះទៅ ប៉ុន្តែលើកយូរទៅៗកើតងងឹតមាន់អស់ហើយ រែកទាំងងងឹតមាន់ វាក្ដៅថ្ងៃ កើតជាងងឹតមាន់អស់ភ្នែកមើលអត់ឃើញវាស្រាំង ដូចថាវាក្ដៅថ្ងៃ ដល់យប់ឡើងត្រូវធ្វើការ គេឲ្យយើងទៅធ្វើទោះបីខ្ញុំមិនឲ្យទៅធ្វើ

ក៏មានគេមកដេញឲ្យយើងត្រូវទៅធ្វើ ព្រោះផងឺតមាន់ ឈឺក៏មន្ទីរពេទ្យនៅកន្លែងដូចថាឈឺគ្រុនផ្ដាសាយក៏យកទៅពេទ្យ ពេទ្យគេទទួល ។

ដារ៉ា : ពេទ្យគេនៅម្តុំណា?

បណ្ឌិត : នៅត្រពាំងថ្ម វត្តត្រពាំងថ្ម ។

ដារ៉ា : វត្តត្រពាំងថ្មតែម្តង ហ្នឹងពេទ្យ?

បណ្ឌិត : ចា៎! ហ្នឹងពេទ្យ ពេទ្យតំបន់ទទួល៤ស្រុក យកទៅដាក់ទៅអ្នកណាឈឺ យើងសរសេរអក្សរទៅឲ្យគេនាំទៅ កងនេះ កងនោះ យកទៅដាក់នោះ ។

ដារ៉ា : អ៊ីចឹងមីងទៅដល់ត្រពាំងថ្ម មីងនៅតែប្រធានកង ឬយ៉ាងម៉េច?

បណ្ឌិត : នៅតែប្រធានកង តែមនុស្សឃើញតែបាត់ព្រោះឈឺ ទៅដេកពេទ្យអស់ ជួនណាបាត់៣០-៤០នាក់ ។

ប្រុញ : ពេលហ្នឹងមានជំងឺច្រើនទេ?

បណ្ឌិត : ឈឺដូចជំងឺជីកទឹករាគ រាករូះ ។

ប្រុញ : ដោយសារទឹកគ្មានអនាម័យ?

បណ្ឌិត : គ្មានអនាម័យសម័យនោះ ឲ្យតែបានផឹកទៅ ទឹកវាមិនសូវសំបូរទេ មនុស្សរាប់ពាន់នាក់នោះ ។

ប្រុញ : អ៊ីចឹងហូបចុកគ្រប់គ្រាន់ទេ?

បណ្ឌិត : ហូបវាមិនសូវជាបរិបូរណ៍ប៉ុន្មានទេ ប៉ុន្តែវាគ្រាន់ជាងយើងនៅ បាយមួយចាន តែទឹកមិនសូវសំបូរ បាយមួយចានព្រឹក-ល្ងាច តែប៉ុណ្ណឹងហើយ ។

ប្រុញ : និយាយទូទៅអ្នកឈឺដោយសារគាត់ហូប?

បណ្ឌិត : ទឹកវាខ្វះ ។

ប្រុញ : ទឹកអត់ស្អាត?

បណ្ឌិត : ទឹកវាមិនសូវសំបូរមនុស្សច្រើន ជីកអណ្តូងតាមរណ្តៅយើងជីក ជួនណាមានចេញទឹកៗយើងត្រូវតែជីកខ្លួនយើង ហើយខែប្រាំងគ្មានទេទឹកនោះ មានតាមស្រះ ហើយស្រះនៅឆ្ងាយត្រពាំង យើងរួចការងារហើយទៅដងៗ មានតែបំពង់ មានតែធុងក៏មានតែ ធុងតែបំពង់ឫស្សីប្រចក ។

ដារ៉ា : កន្លែងស្នាក់នៅ កន្លែងដេក កន្លែងពួន ម៉េចទៅ?

បណ្ឌិត : ខ្ទមទំនប់ ៗ មាត់រណ្តៅ ។

ដារ៉ា ៖ អាមាត់រណ្តៅដែលយើងដឹកដីហ្នឹង?

បណ្ឌិត ៖ ចា៎! មាត់រណ្តៅ ដូចថារណ្តៅប៉ុណ្ណេះទៅ គេធ្វើវេង សព្វថ្ងៃវេងចាំចាប ។

ដារ៉ា ៖ ចាំចាបនៅស្រែហ្នឹង?

បណ្ឌិត ៖ មិនបានស្អាតប៉ុណ្ណោះផង សសរ៤ទៅដាក់ស្មឺៗបាំងពីលើ ចង់មុងដេកទៅ ...បន្តិចបន្តួច ។

ដារ៉ា ៖ ចុះបើភ្លៀងអីមក?

បណ្ឌិត ៖ ភ្លៀងមិនដឹងធ្វើម៉េច អង្គុយទៅ ។

ប្រុញ ៖ ដេក?

បណ្ឌិត ៖ ហាលភ្លៀង បើមិនមានអីបាំង គ្មានកៅស៊ូពីណា ។

ប្រុញ ៖ អត់មានកន្ទេលមានអីក្រាលដេកទេ?

បណ្ឌិត ៖ មានកន្ទេលយើងនាំគ្នាបាំងទៅ បើភ្លៀងមកនាំគ្នាអង្គុយ មានអីបាំង បើយើងមានកៅស៊ូទៅពីផ្ទះ យើងបាំងទៅ អ្នកណាគេមាន គេបាំងទៅ បើភ្លៀងនាំគ្នាអង្គុយទៅ គ្រុបឥវ៉ាន់ឲ្យជិត ចូលត្រសុលឲ្យតែជិតក្បាលទៅក៏ដេក ។

ដារ៉ា ៖ ដេកទាំងភ្លៀងហ្នឹង?

បណ្ឌិត ៖ ចា៎! ដេកទាំងភ្លៀងរួចហើយ ។

ប្រុញ ៖ មីងមេកងធ្វើការដូចគេដែរ?

បណ្ឌិត ៖ ធ្វើតែគេ មិនមែនថាមេកងមិនធ្វើទេ ធ្វើដូចតែគ្នា ។

ប្រុញ ៖ ហើយយើងនៅដើរមើលគេធ្វើ?

បណ្ឌិត ៖ គ្រាន់តែមើល វែករួច ហើយវែកមិនរួច មើលគេគ្រប់ប្តូអត់ ខ្លះគ្នាខ្វះឥលូវហូបបាយសិនទៅ ថាអីចេះ ហូបបាយសិនទៅចាំធ្វើម្តងទៀត សំរាកទៅ ។

ដារ៉ា៖ បន្ទាប់ពីមីង ដូចថាមេកងអីចឹង មានប្រធាន មានអនុប្រធានតទៀត?

បណ្ឌិត៖ មាន! ឈ្មោះ ពុន នៅត្រពាំងថ្ម មិនដឹងជាស្លាប់ អីរស់ ។

ដារ៉ា៖ ហ្នឹងអនុប្រធានមីង?

បណ្ឌិត៖ ចា៎! មួយទៀត ភ្លេចឈ្មោះអស់ហើយពូអើយ ខ្ញុំមិនសូវជាគិត ។

ដារ៉ា៖ សមាជិកក្នុងកងមីងច្រើនអ្នកភូមិនៅណា?

បណ្ឌិត៖ អ្នកថ្មីផង អ្នកស្រុកផង ប្រជាជនចាស់ផង ប្រជាជនថ្មីផង ។

ដារ៉ា៖ ប្រជាជនថ្មីច្រើនមកពីណា?

បណ្ឌិត៖ មកពីខាងស្រុកអីខាងនេះខ្ញុំមិនសូវ ជម្លៀសមកនៅនឹងភូមិ ។

ដារ៉ាៈ អ្នកហ្នឹងពូកែធ្វើការដែរ?

បណ្ឌិតៈ គេមានពូកែអី ដូចតែគ្នា ស្គមស្គាំង ដូចថាគេធ្លាប់ស៊ី ដូចយើងអ្នកស្រែអីចេះ យើងស៊ីមិនសូវនេះ គេធ្លាប់តែហូបចុកឆ្ងាញ់ ដល់ពេលមកលំបាក ក៏ជួបការលំបាកក៏ស្គមទៅ ចង់ស៊ីប្រោចដូចយើងអ្នកស្រែទេ ស៊ីតែពីតែពាស អាស្លឹកអីក៏ស៊ីៗ ស្គាល់ដើមឈើអីចឹងឯងដាងស្រុកស្រែទៅទៀត កាលណាស៊ីទៅបណ្ដាលឲ្យរាករុះ អ្នកស្រុកអ្នកស្រែមិនសូវស៊ីតែពីពាសទេ ទោះអីអត់យើងធម្មតាតែគាត់អ្នកទីក្រុង គាត់ជម្រៀសមកអីចឹងទៅស៊ីដើមឈើដើមព្រៃតែពាស ថាកុំឲ្យស៊ីខ្វាចពុល ដូចដើមប្រមាត់មនុស្ស ខ្ញុំមិនដែលស្គាល់ផងគាត់ស្គាល់អស់ ហូបអស់ ប្រមាត់មនុស្សខ្ញុំរស់ធំប៉ុណ្ណេះខ្ញុំមិនដែលស្គាល់ទេ គាត់ស្គាល់ គាត់ហូប ថាហូបដើមនេះមិនខ្វាចពុលទេ? គាត់ហូបអាហ្នឹងមានអីឆ្ងាញ់ ។

ប្រុញៈ ពេលឈឺមីងមានបានទៅរាយការណ៍ប្រាប់ខាង?

បណ្ឌិតៈ ពេលឈឺយកទៅពេទ្យទៅ ពេទ្យនៅជិត ពេទ្យតំបន់ ។

ប្រុញៈ យើងមិនបាច់រាយការណ៍ប្រាប់ថ្នាក់លើទេ?

បណ្ឌិតៈ ដូចថាយើងឈឺអីចឹងក្នុងកងយើងនាំទៅ ដូចថាឈឺគ្រុនរងាអីណា៎ ថាខ្ញុំគ្រុនហើយបងអើយ គ្រុនទៅពេទ្យទៅឲ្យអ្នកណាមួយជូនទៅ ព្រោះយើងរវល់ជាប់ធ្វើការ គេក៏ជូនទៅដាក់ទៅប្រាប់ពេទ្យ គេកត់ឈ្មោះទុក ពេលយើងជាគេបញ្ជូនយើងមកវិញ បើយើងមិនជាក៏ យើងដេកទៅ ខ្លះជា ខ្លះមិនជាចេះតែដេកទៅ ។

ដារ៉ាៈ មានអ្នកស្លាប់នៅកន្លែងការដ្ឋានហ្នឹងដែរ?

បណ្ឌិតៈ អ្នកស្លាប់មានតែយើងខ្សែស្ទី លោកធំ គេវ៉ៃចោល តែយើងមិនស្គាល់គេ ឃើញ គេខុសអី យើងគ្រាន់តែឃើញចង់ងាប់មុនគេទៅហើយ មិនបាច់ទៅសួរ ទៅនាំទេ ខ្ញុំមិនហ៊ានសួរទេ ទោះបីវ៉ៃនឹងភ្នែកក៏មិនហ៊ានទាំងមើលទៀត ក្នុងទំនប់ងាប់ច្រើនណាស់ ។

ប្រុញ ៈ វ៉ៃក្នុងទំនប់ហ្នឹង?

បណ្ឌិតៈ ងាប់ច្រើន គ្រាន់តែមិនដឹងគេខុសអីទេ យើងមិនដឹង យើងដឹងតែដេក យប់ឡើងអន្ទ្រញដើងឡើងរួញអស់ ខ្លាចងាប់ មិនបាច់ថាឯងប្រធានកង មិនប្រធានកងអីនោះ ឲ្យតែខុសដឹងតែងាប់ ។

ដារ៉ាៈ ហើយអ្នកណាគ្រប់គ្រងមួយអាងត្រពាំងថ្មហ្នឹង?

បណ្ឌិតៈ តាវ៉ាល់ ។

ដារ៉ាៈ តាវ៉ាល់ ហ្នឹងដែរ?

បណ្ឌិតៈ	ខ្ញុំថា តាវ៉ាល់ នោះឯង ក្តាប់ទំនប់នេះហើយ ទំនប់នោះទៀត ត្រពាំងថ្មទៀត គាត់ក្តាប់រួម សព្វថ្ងៃនាប់ហើយ ។

ប្រុញៈ	ពេលធ្វើការនៅត្រពាំងថ្ម មនុស្សច្រើន?

បណ្ឌិតៈ	មនុស្សច្រើនណាស់ ។

ប្រុញៈ	ហើយសល់ពីហ្នឹងទៅ ធ្វើហ្នឹងហើយបញ្ជូនមនុស្សទៅធ្វើឯណាទៀត?

បណ្ឌិតៈ	ស្អានស្រែង ។

ប្រុញៈ	ហើយបញ្ជូនទៅមានមនុស្សច្រើនទេទៅ?

បណ្ឌិតៈ	ទៅច្រើន ទៅស្អានស្រែង ទៅវែក ហើយត្រង់នេះទៅត្រង់នោះ ។

ប្រុញៈ	បើយើងគិតទៅឧទាហរណ៍ នៅត្រពាំងថ្មមានថាឥលូវ១០០០នាក់ ធ្វើទំនប់ហ្នឹងហើយ សល់មនុស្សប៉ុន្មាននាក់ដែលធ្វើនៅកន្លែងផ្សេង?

បណ្ឌិតៈ	ក្មួយអើយ រួចអីចឹងគេឲ្យទៅតាំងអស់ អ្នកណាមិនបានទៅ ខ្ញុំប៉ុណ្ណោះរួច ទំនប់ត្រពាំងថ្មខ្ញុំក៏ចូលពេទ្យ ធ្ងន់ណាស់ ចូលពេទ្យគេឲ្យខ្ញុំ មើលទៅមានលិទ្ធភាព គេឲ្យខ្ញុំធ្វើពេទ្យ ខ្ញុំក៏ឈប់បានលើក លើកបានតែទំនប់ត្រពាំងថ្ម និងទំនប់នេះ ។

ប្រុញៈ	ធ្វើហើយដែរ?

បណ្ឌិតៈ	ហើយៗឡើងឆ្នង ឆ្នងទៅលេង ។

ប្រុញៈ	ហើយប្រហែលខ្ទង់ឆ្នាំណាដែរ?

បណ្ឌិតៈ	ថាខ្ញុំមិនចាំឆ្នាំទេ ហើយ ធ្វើឡើងហើយ ឡើងឆ្នង តែឆ្នងអត់រួច ប៉ុន្តែគេដូលខ្ញុំទៅធ្វើពេទ្យ គេមើលខ្ញុំខាងពេទ្យ គេបញ្ចូលខ្ញុំទៅធ្វើពេទ្យ ធ្វើពេទ្យនោះបានចំនួនប្រហែលមួយឆ្នាំដែរ មួយឆ្នាំរួចគេចាប់អាមេធ្វើពេទ្យ ពួកនិរតីគេមកគេថាឯងខុសអីៗ ដេញចាប់ប្រធានពេទ្យឡើងម៉ត់ ប៉ុន្តែនៅខ្ញុំ ហើយខ្ញុំមកផ្ទះ មកផ្ទះនេះដោយសារចេះអក្សរទេ អត់ចេះអក្សរអត់មករួចទេ សរសេរសំបុត្រកុហកគេ សុំបើកផ្លូវឲ្យដើរ សរសេរពួកវាបែបល្ងង់ដែរក៏មិនដឹង ខ្ញុំសរសេរសំបុត្រសុំបើកផ្លូវឲ្យឈ្មោះនេះ ឈ្មោះ ឡូត បណ្ឌិត ទៅផង ព្រោះអីម្តាយឈឺនៅឯផ្ទះ បែកបាយបែកទឹកឲ្យហូបផង មិនសរសេរអីចេះវាឲ្យស៊ីទេ ចូលក្នុងភូមិក៏ មិនឲ្យដែរ វាចាប់សំបុត្រខ្ញុំមើល ក៏វាឃើញវាឲ្យខ្ញុំនៅ កុំអីមិនឲ្យខ្ញុំនៅទេ ខ្ញុំមកម៉ែខ្ញុំវិញ ។

ដារ៉ាៈ	ដាក់សំបុត្រអីចឹងអ្នកណា?

បណ្ឌិតៈ	ខ្ញុំសរសេរខ្លួនខ្ញុំ ។

ដារ៉ាៈ សរសេរហើយតែដាក់ឈ្មោះអ្នកណា?

បណ្ឌិតៈ ដាក់ឈ្មោះប្រធានខ្ញុំ ។

ដារ៉ាៈ ប្រធានឈ្មោះអីកាលហ្នឹង?

បណ្ឌិតៈ ដាក់ឈ្មោះអ៊ី វ៉ាល់ ឲ្យមកខ្ញុំកុហកទៅ ប្រធានពេទ្យឈ្មោះ បងលុយ ប្រធានពេទ្យខ្ញុំ ថាឲ្យមកផ្ទះមើលម៉ែ មើលឪ ខ្ញុំចេះតែថាៗទៅ បើតឹងរឹងដូចសព្វថ្ងៃត្រូវតែងាប់ តែសម័យនោះវាអត់សូវចេះអក្សរទេ ខ្ញុំហុចតែសំបុត្រវាទៅខ្ញុំចូលទៅក្នុងភូមិស្អាក់ខ្ញុំតាំងដើមផ្លូវ ផ្លូវចូលទៅពែន ខ្ញុំក៏ដកពីសាកាដូខ្ញុំហុចទៅ ហុចទៅវាចាប់បើកមើលឲ្យបើកផ្លូវ ឲ្យទទួលឲ្យនៅផង បានវាឲ្យខ្ញុំនៅ កុំអីអត់ឲ្យនៅទេ ឈ្លបវានៅចាំផ្លូវស្រេច ខ្ញុំសរសេរទៅទេវតាទៅឲ្យខ្ញុំនៅ កុំអីអត់បានជួបម៉ែទេ កុំវាវៃតាមផ្លូវងាប់បាត់ ចូលក្នុងភូមិក៏មិនឲ្យចូលដែរ ខ្ញុំអរណាស់វាមើលសំបុត្រហើយទទួលព្រមឲ្យនៅ ខ្ញុំអរណាស់បានជួបម៉ែខ្ញុំ ខ្ញុំនៅតែម្នាក់ឯង ដែលទៅនៅភ្នំស្រុកនោះណា៎ តែម្នាក់ខ្ញុំទេ ។

ដារ៉ាៈ ពេលដែលនៅត្រពាំងថ្មហ្នឹង ពេលលើកពេលអី មានជាគណៈប្រតិភូ មានអ្នកធំ អ្នកអីគេចុះពិនិត្យមើលដែរ?

បណ្ឌិតៈ ចុះពិនិត្យមើល ។

ដារ៉ាៈ ភាគច្រើនមកពីណា?

បណ្ឌិតៈ ពីស្វាយ តាវ៉ាល់, តាមោង, បងស្អីគេសុទ្ធអ្នកធំ តែងាប់អស់ហើយ ខ្ញុំស្គាល់តែឈ្មោះលឺតែឈ្មោះ យុវជននៅខ្នងទំនប់នេះ ដែលយើងឆាយ ពេលគេមកគេប្រាប់យើងមុនឲ្យយើងធ្វើខ្នងទំនប់ឲ្យស្អាត ពេលមានគេមកត្រួតពិនិត្យ យើងឆាយឲ្យស្អាតទៅ អ្នកឆាយខ្នងទំនប់មិនទាន់ងាប់នៅ ។

ដារ៉ាៈ នៅឯណា?

បណ្ឌិតៈ នៅតារ៉ូង ។

ដារ៉ាៈ គាត់នៅណា តារ៉ូង?

បណ្ឌិតៈ ទៅបៀតមួយជួរភ្នំស្រុកនោះឯង អ្នកធ្វើខ្នងទំនប់ អ្នកវាស់ដី វាស់ខ្នងទំនប់នៅរស់តា៎ មិនទាន់ងាប់ទេ ។

ដារ៉ាៈ ឈ្មោះតារ៉ូង?

បណ្ឌិតៈ ភូមិតារ៉ូង ។

ដារ៉ាៈ គាត់នៅភូមិណា?

បណ្ឌិតៈ ភូមិតាវ៉ូង បងសេង ។

ប្រុញៈ គាត់ឈ្មោះសេង ។

បណ្ឌិតៈ ឈ្មោះ សេង ។

ដារ៉ាៈ តាវ៉ូង ភូមិហ្នឹងនៅម្តុំណា?

បណ្ឌិតៈ នៅភូមិអីមិនដឹង តែភូមិតាវ៉ូងអីចឹងឯង ។

ដារ៉ាៈ នៅឃុំអីគេ តាវ៉ូងហ្នឹង?

អ្នកជិតខាងៈ ឃុំពន្លៃ

ដារ៉ាៈ ឃុំពន្លៃ ។

អ្នកជិតខាងៈ ឃុំពន្លៃ ស្រុកភ្នំស្រុក ។

បណ្ឌិតៈ ហ្នឹងឯងអ្នករាស់ដីទំនប់ ។

ប្រុញៈ គាត់អ្នករាស់ដីទំនប់?

បណ្ឌិតៈ ធ្វើខ្នង ឆាយលើធ្វើខ្នងទំនប់ ទៅសួរមនុស្សតែម្នាក់ហ្នឹង ស្គាល់អ្នកឆាយទាំងអស់ ព្រោះក្រុមគ្នាគាត់ ។

ដារ៉ាៈ មឹងពេលហ្នឹងអ្នកដែលចុះទៅមើលទំនប់ មានតាវ៉ាល់, តា...?

បណ្ឌិតៈ តាមោង ហើយឈ្មោះមួយទៀតមិនចាំឈ្មោះ ។

ដារ៉ាៈ ចុះមានលឺឈ្មោះ យាយថែម ទេ?

បណ្ឌិតៈ យាយថែម មិនមែននៅនេះទេ ។

ដារ៉ាៈ យាយថែម នៅណាវិញ?

បណ្ឌិតៈ យាយថែម មិនដែលនៅនេះទេ យាយថែម ។

ដារ៉ាៈ នៅណាវិញ?

បណ្ឌិតៈ នៅខាងនោះដឹង យាយថែម ដែលមាន ។ ទេ! គាត់មិននៅនេះទេ យាយថែម បើមេទ័ពមានហើយយាយថែម បើតាវ៉ាល់, តាមោង ប្រធានចល័តៗរួមក្នុងមួយតំបន់៥ គាត់សមតែងាប់ហើយ ។

ប្រុញៈ បើសរុបទៅ តាវ៉ាល់ គាត់ដឹកនាំ គ្រប់គ្រង ធ្វើត្រពាំងថ្មហ្នឹងទាល់តែហើយឬម៉េច?

បណ្ឌិតៈ គ្រប់កន្លែងនោះ ។

ប្រុញៈ គាត់ធ្វើហើយទេ?

បណ្ដិតៈ ធ្វើហើយរបស់គាត់ ហើយរបស់គាត់ទាំងអស់ ហើយរួចហើយបានដេញចាប់គាត់ ពួកខ្ញុំរត់ប្រសេកប្រសាច ពួកខ្ញុំកូនចៅគាត់ហ្នឹង រត់ឡើងភ្នែកខៀវ ចាប់ពួកគ្នាគាត់ដែលពួកនិរតីចូលមក សូម្បីតែប្រធានពេទ្យចាប់ឡើងម៉ត់ដែរ ។

ដារ៉ា ៖ ពេលនិរតីចូលមក ចាប់តាវ៉ាល់ តាម៉ងអស់ទៅចឹង?

បណ្ដិត ៖ ចាប់ ចាប់បណ្ដើរៗទៅណាស់ ចាប់តាវ៉ាល់មុន ថាឯងក្បត់ ថាឯងអីចឹងទៅណា ចាប់ទៅគាត់ក៏រត់មិនរួចទេ ចាប់យកទៅបាត់រហូតទៅ ខ្ញុំក៏មិនដឹងថាបាត់ ក្រោយមកខ្ញុំក៏ដឹង ថាចាប់យកទៅ ឲ្យទៅរៀន ថាឲ្យទៅរៀនក៏សម្លាប់ទៅ ថាគាត់ទៅរៀនបាត់ហើយ ។

ដារ៉ា ៖ ហើយចុះ មីងជាប្រធានកងដែរ ជិនាទ់ក្នុងការគ្រប់គ្រង់របស់តាវ៉ាល់ចឹង អត់មានគេតាមដានអីទេ អត់មានពួកនិរតីតាមដានអីទេ?

បណ្ដិត ៖ អត់តាមដានទេ ចាប់តែមេយក វាបែកហើយ វាចង់រួចទំនប់ទៅហើយ ។ រួចហើយគាត់ឆ្លងរួចអស់ហើយ ដែលគាត់មកនៅអាទំនប់ចាន់ចាប់ពីទំនប់ស្ពានស្រែង អាហ្នឹងបែកគ្នាហើយណា គាត់ទៅវិញឥឡូវហើយ ដល់ហើយពួកចល័តរុះអាស្ពានទី១ រួចអស់ហើយទៅអាស្ពានស្រែងនោះទៀត ខ្ញុំឯងនេះក៏ចូលឯកន្លែងពេទ្យឯនេះ ដល់ពេលគេយកខ្ញុំទៅដាក់កន្លែងពេទ្យក៏ធ្វើពេទ្យទៅ ខ្ញុំក៏ចូលធ្វើទេព្យទៅ ឯគាត់ក៏ត្រឡប់ទៅរកប្រពន្ធគាត់ទៅចាប់ ចាប់នៅផ្ទះរបស់ប្រពន្ធឯនេះទេ ចាប់នៅឯ ជប់នេះ ។

ដារ៉ា ៖ ជប់នេះ?

បណ្ដិត ៖ ចា៎ ផ្ទះប្រពន្ធគាត់នៅជប់នេះ ត្រឡប់ពីមកវិញមិនដឹងចាប់ពីកាលណាទេ ចាប់ទៅ ។

ដារ៉ា ៖ យើងទៅពេទ្យហ្នឹង ពេទ្យអីគេមីង?

បណ្ដិត ៖ ពេទ្យយើងទូទៅហ្នឹង

ដារ៉ា ៖ នៅផ្ដុំណាំមីង?

បណ្ដិត ៖ នៅវត្តត្រពាំងថ្នូហ្នឹង

ដារ៉ា ៖ វត្តត្រពាំងថ្នូហ្នឹង!

បណ្ដិត ៖ ឲ្យទៅរៀនពេទ្យ មានពេទ្យឆ្មប មានពេទ្យអីហ្នឹង មានពេទ្យប្អូនមុខ ។

ដារ៉ា ៖ មីងពេទ្យខាងអី?

បណ្ដិត ៖ ធ្វើទូទៅ ។

ដារ៉ា ៖ ធ្វើទូទៅ?

បណ្ឌិត ៖ អ្នកត្រូវគ្រាប់ឲ្យទៅវះ ខ្ញុំចេះតែទៅណាស់ ឲ្យទៅដេរខ្ញុំចេះតែដេរទៅ បន្ទាប់ឲ្យដេរចេះៗទៅណាស់ ហើយអ្នកប្រជាជនទាំងនោះចេះតែទៅរក...... ឲ្យខ្ញុំទៅដេរ ដែតអើយទៅដេរអ្នកជម្ងឺឯនោះ ខ្ញុំក៏ទៅដេរទៅ បន្ទាប់ឲ្យដេរចេះៗទៅណាស់ នោះប្រធានពេទ្យឈឺ អន់លុយ ប្រធានពេទ្យរង៉ម៉ាតំបន់ បួនស្រុកនោះណា គេហៅថាប្រធានពេទ្យ គាត់ថាហងទៅដេរទៅ ខ្ញុំនៅក្មេងថា ដេរយ៉ាងណាបងចាក់ចេះមួយៗទៅម្ហូលមានហ្ន៎ តែថ្នាំមិនសូវសម្បូរទេ ថ្នាំមានតែថ្នាំដែលយើង រាយអន្ទាសពីដើម ដែលយើងសើរើចាប់បានតាមនេះហ្ន៎ មានគ្រាកូតាខាំចៃ ស្ត្រេីន មានអីចឹង អត់មានថ្នាំល្អដូចយើងសព្វថ្ងៃនេះទេ តើយើងឈឺអីធ្ងន់ទៅមានតែសង្គមកិច្ចយើងសព្វថ្ងៃ កាលមានពីសង្គមអាពតហ្នឹង ដែលធ្វើហ្នឹងកាលនោះពេលដែលគ្រុនខ្លាំង មានថ្នាំចាក់នប្តិចបន្តួច មិនសូវសម្បូរទេ វាមានអាថ្នាំមិនត្រូវរោគយើង វាមានខ្វះដែរថ្នាំ ព្រោះថាគ្រាកូទឹក គ្រាអីនោះ ។

អ្នកភូមិ ៖ ថ្នាំវាមិនខ្វះ មកពីអ្នកប្រើវាមិននេះ ។

បណ្ឌិត ៖ ទេ មានគេចេះជាងយើងទៅទៀត តែគេមិនបញ្ចេញ មានសុទ្ធតែអ្នកចេះ តែគេមិនអាចអួតខ្លួនថាគេចេះទេ ហ៊ានតែអួតខ្លួនថាអ្នកចេះច្បាស់ពិតជាបាត់ខ្លួនយប់នេះហើយ អត់មានរស់នៅបានទេ ចំពោះអ្នកចេះរស់នៅមិនបានទេ ។

ប្រុញ ៖ ទោះបីចេះថ្នាំក៏ដោយ?

បណ្ឌិត ៖ ចេះថ្នាំកើត ទាល់តែយើងចេះថ្នាំអក្សរបារាំងអីនេះ យើងនេះវណ្ណៈខ្ពស់ហើយ គេថាវណ្ណៈសក្តិភូមិនៅសម័យគេថាចឹង ស៊ើបពីប្រវត្តិយើងភ្លាមនោះឯង ស៊ើបប្រវត្តិយើងភ្លាមខ្ញុំគ្រាន់កវាថា ខ្ញុំនេះកូនសក្តិ ប្រាំ សក្តិប្រាំមួយនោះ កាលនោះខ្ញុំសស្គុះ ទៅនៅចេះទៀត ។ ... ទេយាយចែមនៅតំបន់យើងតើ ... មិនស្គាល់ទេ ។

ដារ៉ា ៖ ចឹងពេលមីងមកដល់ពេទ្យហ្នឹង នៅរយៈពេលប៉ុន្មាន?

បណ្ឌិត ៖ បានរយៈពេលមួយឆ្នាំ ។

ដារ៉ា ៖ បានមួយឆ្នាំ! ហើយអ្នកឈឺច្រើនមកពីណាមីង?

បណ្ឌិត ៖ ឈឺច្រើនមកពីចល័ត ។

ដារ៉ា ៖ ឈឺភាគច្រើនឈឺអី?

បណ្ឌិត ៖ គ្រុនក៏រាគ ខ្លះក៏ឈឺពោះ ហើម អាខ្លះរលាកស្បូន ថ្លោះចង្កេះ វាមានគ្រប់រឿងគ្រប់ជម្ងឺទាំងអស់ ចុះវាឡើងបួនស្រុកឯណោះ អ្នកជម្ងឺវាឡើងបួនរយ ស្រីពីរយប្រុសរយ មិនតិចណា មានគ្រប់តែរោគ អ្នកខ្លះក៏ស្គម អ្នកខ្លះក៏ធាត់ប៉ុន្នេះ ។

ដារ៉ា ៖ មកហ្នឹងព្យាបាលជាទេ មីង ភាគច្រើន?

បណ្ណែត ៖ ខ្ចះរលាកស្បូនលោកអើយ អត់មានថ្នាំចាក់ ថ្នាំលៀប មានក៏ត្រូវរោគក៏ទៅបាត់ទៅ បើយើងមិនជាទេ ធ្វើជាអត្តបទអ្នកជម្ងឺទៅ ថាចាក់ថ្នាំអីមិនជាទេ ក៏ធ្វើអត្តបទទៅលើ ខាងស្វាយ និយាយទៅក៏គេមក ឡានពីរគេមកដឹកយកទៅ ខាងស្វាយយើងនេះ ពីភ្នំស្រុកបើកឡើងទៅវិញភ្លាម ឡានគេមកដឹកទៅ អ្នកជម្ងឺធ្ងន់ៗដែលយើងមិនអាចមើលជាយើងក៏ ធ្វើអត្តបទតាមពេទ្យពេលដែលគេទៅបើកថ្នាំទៅ ឡានគេក៏មានមកណា ចឹងក៏យើងផ្ញើរតាមក្រដាស់ហ្នឹងទៅថាឲ្យគេមក ឲ្យគេមកយកអ្នកជម្ងឺ លីចេះមួយចុះមួយ ទៅមើលទៅព្យាបាលវាមិនជាទេ បង់ឯងចុះមកយកទៅ យើងក៏មើលថ្នាំអីហើយ ដាក់ថ្នាំអីហើយ ដាក់ឈ្មោះថ្នាំទៅឲ្យគេទៅ ថ្នាំនេះយើងឲ្យលេបហើយ ថ្នាំនោះយើងឲ្យ លេបហើយនៅតែមិនបាត់មុខថ្នាំនេះថ្នាំនោះទៅប្រាប់គេ ក៏គេមើលតាមក្រដាស់ដែល យើងឲ្យគេទៅ ក៏គេយកអ្នកជម្ងឺហ្នឹងទៅ កត់ឈ្មោះកត់អីឲ្យគេទៅ ចំនួនម្តងតែ ដប់នាក់ ទៅឈឺជម្ងឺធ្ងន់ៗ ឈឺត្រង់ណាដំបៅត្រង់ហ្នឹង កើតតែបូសដង្កូវរុក ខ្ញុំឈរចាប់ទាល់យប់នៅតែមិនជា មិនសូវសម្បូរថ្នាំ ច្រើនតែអ្នករោគមួលច្រើន ។

ដារ៉ា ៖ ច្រើនតែរោគមួលខ្លាំងមែនទែន?

បណ្ណែត ៖ រោគមួលវាច្រើន រោគមួលរោគឈាមដូចយើងដុះឈាមចឹងច្រើនដែរ អ៊ួយខ្ញុំឆ្អែតហើយជាមួយអ្នកជម្ងឺ ។

ដារ៉ា ៖ អ្នកឈឺមកពីណាដែរ មកពីត្រពាំងថ្ម រឺមកពីអី?

បណ្ណែត ៖ ចាំ មកពីត្រពាំងថ្ម អ្នកជម្ងឺដូចថា អ្នកជម្ងឺមកពីគ្រប់មុខព្រួញមកចូលកន្លែងហ្នឹងទាំងអស់ ។

ប្រុញ ៖ មុនមីងថាធ្វើនៅត្រពាំងហើយ

បណ្ណែត ៖ មកកន្លែងពេទ្យ ។

ប្រុញ ៖ មកកន្លែងពេទ្យ! ចឹងនៅមានអ្នកជម្ងឺមកពីត្រពាំងថ្មទេ?

បណ្ណែត ៖ អាត្រពាំងថ្មនេះមានរួចហើយណា គេបែករំលែកទៅខាងស្ពានស្រែង ទៅខាងរំដួល ស្ពានឡូតិ៍ទី១ដែរ អាទំនប់គេថតហ្នឹង ស្ពានឡូតិ៍ទី១ ហើយតាមសហករណ៍ស្រុក អាមួយតាមស្រុកយើងទៅចេះទៅហ្នឹង ទៅធ្វើស្រែចេះទៅធ្វើអីទៅ ពេលមានឈឺកើតឡើងទៅកន្លែងពេទ្យហ្នឹងទៅ ថាពេទ្យតំបន់មានទទួលបួនស្រុក អ្នកជម្ងឺណាគេមិនថារើសមុខទេ ថាអ្នកជម្ងឺណាទេ ធ្ងន់យកទៅដាក់ទៅ បួនស្រុកទទួល ។

ប្រុញ ៖ ពេលអ្នកមីងធ្វើការនៅពេទ្យហ្នឹងមានអ្នកជម្ងឺមកពីត្រពាំងថ្មទេ ដែលគាត់ធ្វើការធ្វើត្រពាំងថ្ម?

បណ្ឌិត ៖ មក អានោះក៏មករួចហើយណា បញ្ជូនអ្នកជម្ងឺទៅខាងស្ពានស្រែង អោះ បញ្ជូនអ្នកជាទៅខាងស្ពានស្រែង បើមានអ្នកខាងណោះឈឺបញ្ជូនមកពេទ្យនោះហើយ ពេទ្យនៅបួនស្រុកទទួល ឲ្យតែស្រុកភ្នំស្រុកឈឺក៏បញ្ជូនមកដែរ ស្រុកព្រះនេត្រព្រះឈឺ ដែលថាទៅធ្វើការនៅកន្លែងតំបន់ គេហៅថាកន្លែងតំបន់ វីក៏បញ្ជូនខាងមនុស្សថ្មពួកឈឺ ក៏ចូលកន្លែនោះដែរ គឺថាទទួលមកបួនស្រុក លើកទំនប់នោះមានបួនស្រុក បើថាឈឺគឺបញ្ចូលកន្លែងនោះឯង បើថាលើក តែវាលើករួចហើយណា ឆ្នងដល់រួច ធ្វើឆាយដីឡើងស្អាត ឆ្នងរួចទៅ ទៅលើកខាងស្ពានស្រែងទៀត អត់មានកម្លាំងអីមកជួយដូច គោយន្ត អាត្រាក់ទ័រ អីមកជួយទេ វែកតែកម្លាំងមនុស្សទេ វែកចង់ងាប់ មានថាអ្វី យកអាត្រាក់ទ័រ គោយន្តអីទេមកជួយចូកមានទេ វែកតែកម្លាំងចង់ងាប់ បង្គីប៉ុណ្ណោះៗវែក ។

ប្រុញ ៖ មីង សុំសួរមីងកាលមីងធ្វើការនៅត្រពាំងថ្មគេហៅទៅប្រជុំញឹកញាប់ទេ?

បណ្ឌិត ៖ ប្រជុំ ប្រជុំឲ្យជម្រុញ ។

ដារ៉ា ៖ គេប្រជុំហៅតែមេកង ឲ្យទៅប្រជុំ?

បណ្ឌិត ៖ ពេលប្រជុំមេកងរួច គេឲ្យមើលកំហុសគ្នា តើខ្ញុំនេះមានធ្វើខុសអី គេឲ្យឆ្លើយ តើមានក្នុងកងក្នុងវរៈនេះ តើអ្នកណាមានខុសសីលធម៌អី ស្រលាញ់ស្រីស្រលាញ់អីហ្នឹងណា មានសង្សារមានអីមិនបានទេ មិនត្រូវទាក់ទងប្រុសឈ្មោលមានទេ ហើយសួរយើងថាមានឃើញទេ អ្នកណាមានកំហុសអីអត់ ខ្ញុំឆ្លើយថាមិនឃើញ គ្មានអ្នកណាមានកំហុសអីទេ បើបងឯងឃើញកំហុសខ្ញុំតិទៀន កសាងខ្ញុំទៅចំពោះខ្ញុំ ខ្ញុំមិនឃើញអ្នកណាទេ ហើយក៏ហីទៅ មិនចង់មានអីសៅម៉ង យើងកុំចង់ឃើញកំហុសគេនាំតែមានរឿង ថាមិនឃើញទៅ ។

ដារ៉ា ៖ តើញឹកញាប់ទេ ការប្រជុំហ្នឹង?

បណ្ឌិត ៖ បើយើងមានកំហុស បើខ្ញុំឆ្លើយថាពូឯងមានកំហុសអី ទៅសម្លាប់ចោលងាប់ បើខ្ញុំមិនឃើញក៏ហីទៅ ។

ដារ៉ា ៖ ចង់និយាយថា ការប្រជុំបែបហ្នឹងមានញឹកញាប់ទេ?

បណ្ឌិត ៖ ញឹក ម៉ាអាទិត្យប្រជុំម្តង ដប់ថ្ងៃប្រជុំម្តង ជម្រុញអ្នកលើកដីឲ្យលើកឆាប់រួច ពង្រីងគោលដៅហរអីទៅណា ឲ្យលើកខំលើកកុំនៅចំអែចំអន់ កុំទំរុនស្មុកកុំចាំតែឲ្យគេថានោះ ឲ្យយើងខំលើកខំអីឲ្យឆាប់រួចឆាប់អីទៅ ដប់ថ្ងៃប្រជុំម្តង ។

ប្រុញ ៖ ពីណាគេ?

បណ្ឌិត ៖ ប្រធានក្តាប់រួម ។

ប្រុញ ៖ ប្រធានក្តាប់រួម តាវ៉ាល់ហ្នឹង?

បណ្ឌិត ៖ ចា៎ ហៅពីណារួច តាវ៉ាល់ធ្វើរួច ប្រធានកងវីរៈធ្វើរួម ឲ្យយើងទំលើកដីលេកអីឲ្យលឿន ទាន់សភាពការណ៍ កុំឲ្យទំរុនស្លក់ ធ្វើជាឈឺជាអីទៅណា ។

ប្រុញ ៖ ភាគច្រើនជួបជាមួយតាវ៉ាល ប្រជុំ?

បណ្ឌិត ៖ ប្រជុំ ដូចថាគេដាក់ផែនការមក យើងទទួល ប្រធានវរៈក៏ទទួល ប្រធានវរៈទទួលហើយ ក៏បញ្ចេញមកឲ្យប្រធានកងដាក់កាងារឲ្យយើងធ្វើ ត្រូវបន្ទិចេះមួយចុះមួយឲ្យឆាប់ទៅណា ។

ដារ៉ា ៖ តែអាហ្នឹងសម្រាប់តែស្ពានទីមួយទេមីង?

បណ្ឌិត ៖ ចា៎!

ដារ៉ា ៖ ចុះ ស្ពានទីពីរ?

បណ្ឌិត ៖ ស្ពានទីពីរខ្ញុំមិនស្គាល់ទេ វាស្គាល់ដែរ តែមិនស្គាល់មនុស្សអ្នកណាលើកដីដូចជា ប្រធានកងអី យើងអត់ស្គាល់គេណា តាមកន្លែងរៀងៗខ្លួន មានក្តាប់រួមរៀងៗខ្លួន តែយើងថាទៅមើលៗណា តែយើងមិនដឹងថាអ្នកណាប្រធានកង ប្រធានអីទេ ។

ដារ៉ា ៖ មីង និយាយអាស្ពានទីមួយ តាវ៉ាល់គាត់គ្រប់គ្រងអាហ្នឹង?

បណ្ឌិត ៖ ចា៎ គាត់នៅស្ពានទីមួយ តែគាត់ដើរគ្រប់គ្រងស្ពានទីពីរ ទីបី ម៉ារួមទាំងអស់គឺលើគាត់ទាំងអស់ ។

ប្រុញ ៖ មីងធ្លាប់បានរាយការណ៍ពីអ្នកជម្ងឺស្លាប់ ជម្ងឺអីប្រាប់ដល់តាវ៉ាល់អីដែរ?

បណ្ឌិត ៖ អារឿងស្លាប់មិនបាច់ប្រាប់គេទេ ដូចថាជម្ងឺនេះវាធ្ងន់ សុំច្បាប់គេថាជម្ងឺនេះវាធ្ងន់ ប្រាប់គេថា យើងមិនបាចរាយការណ៍ទៅតាវ៉ាល់ទេណា រាយការណ៍ទៅប្រធានវរៈយើង ថាអ្នកជម្ងឺនេះវាធ្ងន់ហើយ បងហ្អែយត្រូវយកទៅពេទ្យចំនួនប៉ុណ្ណេះនាក់ ថ្ងៃនេះធ្វើការបានចំនួនប៉ុណ្ណេះនាក់ ប៉ុន្តែអ្នកជម្ងឺនេះជាងបួន-ដប់នាក់ហើយ ខ្លះគ្រុន ខ្លះឈឺពោះ ខ្លះអីទៅ ក្នុងម៉ាថ្ងៃយើងត្រូវមើល ក្នុងកងឈឺប៉ុន្មាន ចេញប៉ុន្មាន ចូលប៉ុន្មាន បើថាឈឺដប់នាក់រាយការណ៍ប្រាប់គេថាដប់នាក់ទៅ ថ្ងៃនេះឈឺដប់នាក់ធ្វើការបានប៉ុណ្ណេះទេ ក្នុងបញ្ជីយើងមានរាល់ថ្ងៃ ។

ដារ៉ា ៖ ចុះមីងធ្លាប់ធ្វើបញ្ជីផ្ញើរទៅកងវរៈអីចឹងភាគច្រើន អ្នកដែលមីងធ្វើបញ្ជីផ្ញើទៅហ្នឹងគឺ ភាគច្រើនមានត្រឡប់មកវិញវីក៏បាត់រហូត?

បណ្ឌិត ៖ ទេ ធ្វើបញ្ជីយកទៅថាឈើ ចំនួនដប់នាក់ចឹងយកពេទ្យទៅ ថាថ្ងៃនេះឈឺពោះដប់នាក់ គ្រាន់ថាប្រាប់គេឲ្យដឹងណា គេមិនបានយកទោសម្ងាប់អីទេ ។

ដារ៉ា ៖ មានឃើញត្រលប់មកវិញទេអ្នកដែលឈឺ?

បណ្ឌិត ៖ បើជាទៅឃើញត្រលប់មកវិញ បើមិនជាទេយើងទៅមើល ទៅសួរសុខទុក្ខ បានគ្រាន់អីៗដែរ ។

ដារ៉ា ៖ មានការអនុញ្ញាតទៅសួរសុខទុក្ខគេដែរ?

បណ្ឌិត ៖ ទៅសួរ ខ្ញុំទៅសួរបានគ្រាន់អីហើយទៅដេកពេទ្យហ្នឹង នៅបងមិនទាន់ជា អីចឹងខំលេប ខំផឹកថ្នាំ ចេះទៅចឹងទៅគ្នាមានកម្លាំងចិត្តស្គាល់គ្នាត្រូវគ្នានៅជាមួយគ្នា ខំលេបថ្នាំលេបអីទៅឆាប់ជា នៅឲ្យជាតិចសិនទៅនៅមក ថាចេះប្រាប់ចេះទៅ ។

ប្រុញ ៖ កាលជំនាន់ហ្នុងមានក្រុមពិសេសណាមួយដែលថាតាមដានអ្នកធ្វើការនៅហ្នឹងអត់ទេ?

បណ្ឌិត ៖ មាន មានយោធាគេនៅប្រចាំកន្លែងតារ៉ាល់ហ្នឹង ចំនួនគេម៉ាកង អ៊ូម៉ាក្រុមគេដប់នាក់ ។

ដារ៉ា ៖ មើលតាំងមេកង មេទាំងអីទាំងអស់?

បណ្ឌិត ៖ មើលថាយើងខុសសីលធម៌ យើងស្រឡាញ់គ្នា គេនៅតាមយើងបើយើងមិនមានក៏ហីទៅ

ប្រុញ ៖ ហើយយោធាហ្នឹងរាយការណ៍ឲ្យតារ៉ាល់ ។

បណ្ឌិត ៖ បើយើងខុសរាយការណ៍ភ្លាមចាប់ភ្លាមមិនទុកដល់ស្អែកទាន់ទេ
បើសិនយើងមិនមានការផាវខុសសីលធម៌អីទេក៏ហីទៅ នៅតែយើងអត្តយចេះទៅ បើយើងមិនមានខុស ។

ដារ៉ា ៖ ចាប់ភ្លាមៗ?

បណ្ឌិត ៖ ចាំ អត់បាច់ទុកយូរទេ ស៊ើបព្រោះអីដេកមិនបានទេ បើខុសសីលធម៌ដេកមិនបានទេ លូនដូចស្អីចេះឯង បើរោងកម្ពស់នេះលូនដល់ទាប លូនទៅស្តាប់យើង បើយើងខុសសីលធម៌ណា បើយើងស្រឡាញ់គ្នាអីណា បើយើងស្រឡាញ់ឃើញ រាយការណ៍ ប្រាប់ប្រធានកងថាខ្ញុំស្រឡាញ់រូបនេះ ។

ដារ៉ា ៖ អាហ្នឹងអត់អីទេ?

បណ្ឌិត ៖ ខ្ញុំចង់ស្នើរចេះទៅ បើគេព្រមរៀងការ ការមានអីទេ ចាក់តែមេក្រូ ដាំបាយស៊ីតែគ្នាយើងទៅ គ្មានបាយច្រើនទេនោះឯងយើងរាយការណ៍ឲ្យគេទៅ បើយើងទៅស្រឡាញ់គ្នាទៅជួបគ្នាអីគ្មានរស់ទេ គេថាម៉ែឪឲ្យមកសាកាដូមួយទៅវិញ សាកាដូពីរ គេត្រូវការមើល

យើងឲ្យបានខុសត្រូវកុំឲ្យមានសីលធម៌ គេមិនឲ្យមាន បើកុំតែតឹងចឹង ដូចគេថាចឹងដើម អស់មែន ចុះប្រុសនៅម៉ាគុប ស្រីនៅម៉ាគុប អត់មានទេបើចង់បានស្នើរគេឲ្យ ទៅតាមប្រធានកងទៅស្រីៗ បើប្រុសនោះឲ្យប្រធានកងប្រុស បើចង់បានពូឯងចេះទៅខ្ញុំត្រូវទៅសួរឲ្យឈ្មោះមកក្លាមចង់បានកូនមិត្តឯង ឈ្មោះនេះឈ្មោះនោះទៅ យើងក៏ទៅសួរអីឲ្យគេទៅរូបនោះមកស្នើរចេះយកទេ ទេខ្ញុំមិនយក បើមិនយកក៏ប្រាប់គេថាមិនយកទេ បើសួរទៅថាគេយកក៏យកទៅ ហើយក៏រៀបការឲ្យទៅ បើថ្ងៃទី៣១ រៀបការសាមសិបគូ តាមវេៈផ្សេងៗគេយកមកដាក់ជូនណា ហើយការជុំគ្នាទាំងអស់ ។

ដារ៉ា : មានពិធីហ្នឹងដែរ?

បណ្ឌិត : មាន ការចល័ត ។

ដារ៉ា : នៅកន្លែងការដ្ឋានហ្នឹង?

បណ្ឌិត : ចាំ នៅកន្លែងស្ថានទីមួយហ្នឹង ជួនកាលនៅកន្លែងស្ថានទីបី ក៏មានយកទៅការហ្នឹង កង យើងហ្នឹងយកទៅដាក់ក្រុមគេការជាមួយគ្នាក៏មាន មានតាមរបៀបគេធ្វើហ្នឹង ខ្លាចយើងហ្នឹងវាវល់វេក បើយើងព្រហើនដឹងតែងាប់ ។

ដារ៉ា : ចុះការហើយ?

បណ្ឌិត : វែកដីទៅ ។

ដារ៉ា : អត់មាននៅជាមួយគ្នាទេចុះ?

បណ្ឌិត : នៅជាមួយគ្នា ប៉ុន្តែវែកដី ។

ដារ៉ា : ចង់និយាយថា ក្រោយពីវែកដីមក គេឲ្យនៅជាប្តីប្រពន្ធវឹគេបំបែក?

បណ្ឌិត : ទេ គេមិនបំបែកទេនៅជាមួយគ្នា ប៉ុន្តែវែកដីទៅ ។

ដារ៉ា : បើយើងអត់ការស្រីៗនៅស្រី ប្រុសៗនៅប្រុស?

បណ្ឌិត : បើពូឯងយុទ្ធជនចេះ ខ្ញុំនារីចេះនៅរៀងខ្លួននៅតាមកង បើការរួចចេះនៅជាមួយគ្នាទៅខ្ទមឯងប៉ុណ្ណាក៏នៅទៅ ។

ដារ៉ា : មានខ្ទមទៀតសម្រាប់អ្នកការហ្នឹង?

បណ្ឌិត : ចាំ ការហើយក៏នៅក្នុងខ្ទមយើងទៅ ក៏វែកដីទៅដូចកាលដែលយើងនៅលីវនេះឯង រកចេះឯង ដល់យូរៗស្អិតអស់ហើយវែកដីបាត់ឈឺបាត់អីហើយស្នាហ្នឹង ។

ដារ៉ា : ស្មានថា ការហើយចឹងបានត្រឹមម៉ាការ ចឹងហើយក៏បំបែកគ្នាទៅ?

បណ្ឌិត : ទេនៅជុំគ្នាទៅ ។

ដារ៉ា ៖ ចឹងមានន័យថា មានកន្លែងស្រីៗនៅ មានកន្លែងប្រុសៗនៅ នឹងមានកន្លែងនាក់គេរៀបការនៅ?

បណ្ឌិត ៖ នៅពេលការគេធ្វើដូចរោងមួយ គេដាក់យើងឡើងការចាប់ដៃគ្នាទៅ គេសម្ភាសឲ្យលឺទៅ គេក៏ធ្វើរោងប៉ុណ្ណេះទៅ ពួកយើងក៏អង្គុយដើងម៉ាចេះទៅ ដូចពួងឯងអង្គុយទល់មុខខ្ញុំចេះ ហើយក៏ចាប់ដៃគ្នាទៅ គេក៏ឲ្យពរចាក់ភ្លៀងការសម័យអាពាតតិចទៅក៏ចប់ ។

ប្រុញ ៖ ពេលហ្នឹងស្រលាញ់មនុស្សម្នាក់ចឹង យើងស្នើរគេ?

បណ្ឌិត ៖ ស្នើរតាមមេកង ប្រាប់មេកងយើង ។

ប្រុញ ៖ ចុះនារីហ្នឹងទើបមានអាយុ ដប់បួន ដប់ប្រាំឆ្នាំចឹង តើអាចឲ្យគាត់ការបានទេ?

បណ្ឌិត ៖ យើងមិនអាចបង្ខំគេបានទេ ស្រាច់ថាគេយក បើអ្នកឯងមិនក៏ហីទៅ ។

ប្រុញ ៖ បើនារីហ្នឹងមិនយក មិនមានការបង្ខំពីអង្គការទេ?

បណ្ឌិត ៖ ទេ បើយើងមិនយកក៏ហីទៅណា ដូចថាពូនេះចង់បានអានាងឯងយកទៅចឹងណា ទៅប្រាប់មេកងទៅ ។

អ្នកភូមិ ៖ កាលសម័យហ្នុង គេបែងចែក កងកុមារនៅកងកុមារ កងយុវជននៅកងយុវជន វាអត់មានទាន់ក្រុមអាយុអីទេ ។

បណ្ឌិត ៖ កងកុមារនៅតាមកងកុមារ គេមានប្រធានគេផ្សេង ទាល់តែអាយុប៉ុណ្ណេះៗ រែកដីតិចៗ បង្គីរប៉ុណ្ណេះទៅ កងកុមារ បើយើងធំៗបង្គីធំទៅ ។

ដារ៉ា ៖ គេហៅថាកងនារី?

បណ្ឌិត ៖ កងនារី កងកុមារនារីផ្សេង កងកុមារប្រុសផ្សេង គ្មានដាក់ជុំគ្នាវល់វេកទេ ទោះបីតូចប៉ុណ្ណោះក៏ដោយ ។

ប្រុញ ៖ កងនារី គេគិតចាប់ពីអាយុប៉ុន្មានទៅ?

បណ្ឌិត ៖ នារីខ្លះក៏ ប្រាំបី ម្ភៃទៅ កុមារខ្លះក៏តូចអេកប៉ុណ្ណេះទៅ នៅផ្សេងៗទៅ កុមារប្រុសផ្សេង កុមារស្រីផ្សេង មានគេក្តាប់តាមគ្នាផ្សេងៗគ្នាទៅ អត់មានវល់វេកលាយគ្នាទេ ម៉ាកាដុបៗរៀងខ្លួនៗ គ្មានច្រលុកច្រលំបានទេ យើងកងនារីតាមកងនារី កងយុវជនតាមកងយុវជននៅម៉ាកាដុបម្នាក់ បើយើងចង់បានយើងមានខ្សែរយៈទៅ ចង់បានឃើញនាងនោះដើរចឹងទៅ យើងរែកដីហើយយើងនៅលើនេះ ហើយដើរទៅមុជទឹកឲ្យគេឃើញទៅ បើយើងចង់បានចឹងយើងទាក់តាមមេកងយើងប្រុស ហើយប្រធានកងប្រុសនោះទៀតទាក់ទងមកប្រធានកងនារីស្រី ប្រធាននារីឲ្យសួរឲ្យប្រធានកងគេឲ្យមកនិយាយថា ចង់បាននាក់នេះ

កូនកន់ខ្ញុំចង់បានមិត្តនោះ តើអាចនិយាយបានទេ បើនិយាយបានក៏សួរឲ្យផង យើងក៏ទៅសួរកូនកន់យើងទៅថា មានខាងយុវជននោះ ឈ្មោះនោះចង់បានមិត្តឯង តើមិត្តឯងយកដែរទេ។

ដារ៉ា ៖ មិនទាន់ឃើញគ្នាផង?

បណ្ឌិត ៖ ទេ គេឃើញយើង តែយើងអត់ឃើញគេ ប្រាប់តែឈ្មោះទៅ។ ចាំ! យកប្រាប់ថាយកទៅ មិនយកប្រាប់ថាមិនយកទៅ អាចមានពេលគិត គិតទៅគេមិនទាន់បង្ខំយើងទេ យកក៏យកទៅ មិនយកក៏ហីទៅ។

ដារ៉ា ៖ មីង ជាទូទៅការការហ្នឹងកើតឡើងដោយសារការស្នើរចឹង រឺក៏មានពេលវដូវណាមួយដែលត្រូវអង្គការរៀបចំឲ្យរៀបការ?

បណ្ឌិត ៖ អត់ទេ តាមពាក្យស្នើរគ្នា គេមិនយកក៏មិនអាច នៅកន្លែងចល័ត បើកន្លែងផ្សេងខ្ញុំមិនដឹងទេណា តែនេះកន្លែងចល័តពួកខ្ញុំនៅណា ស្នើរបើគេមិនយកក៏នៅទៅ បើគេយកក៏យក គេមិនយកមានពាក្យថា ខ្ញុំមិនទាន់យកទេ គេឆ្លើយថាចេះណា ខ្ញុំមិនទាន់អាចយកទេ ខ្ញុំធ្វើការឲ្យអង្គការ ខ្ញុំនៅក្មេងខ្លីណាស់មិនទាន់ចង់ កសាងគ្រួសារទេ គេអាចនិយាយថាចេះនោះគេមិនទាន់យកយើងទេ គេនៅក្មេងខ្ចីមិនអាចទាន់កសាងគ្រួសារបានទេ គេមិនយក។

ប្រុញ ៖ អង្គការមានកំណត់ថា ម៉ាឆ្នាំការប៉ុន្មានដងអីទេ?

បណ្ឌិត ៖ អាហ្នឹងអាស្រ័យអ្នកស្នើរបានប៉ុន្មានគូរគេការទៅ បើថាថ្ងៃទីប៉ុណ្ណេះ បើបានច្រើនហើយរាយការណ៍ឡើងទៅលើដល់ គាវ៉ាល់ទៅថាត្រូវរៀបការនៅថ្ងៃទីប៉ុន្មាន ថាថ្ងៃទី៣០ទី១ស្រេចគាត់កំណត់មកឲ្យយើង ធ្វើអានេះប្រាប់គាត់ទៅថាប៉ុន្មានគូប៉ុន្មានគូទៅណា ហើយក៏រៀបការទៅ។

ប្រុញ ៖ មីងមានដឹងថា គេបង្កើតការដ្ឋានត្រពាំងថ្មនេះឡើងដើម្បីអ្វី?

បណ្ឌិត ៖ ដើម្បីទប់ទឹក។

ប្រុញ ៖ ទប់ទឹក! តើគេមានប្រាប់ថា ទប់ទឹកដើម្បីអីខ្លះ?

បណ្ឌិត ៖ សម័យអាពតហ្នឹង គេឲ្យតែលើកហ្នឹង មិនធ្វើអីទេ យើងគិតតែលើកទៅ តែក្នុងចិត្តខ្ញុំគិតថាទប់ទឹក ឲ្យវាជាប់ធ្វើជាអាង ធ្វើជាអាង ធ្វើជាទំនប់ គេហៅថាអាងត្រពាំងថ្ម។

ប្រុញ ៖ តើគេមានប្រាប់យើងទេ?

បណ្ឌិត ៖ គេអត់មានប្រាប់យើងថាជាស្អីមួយទេ ដល់សម័យនេះគេថាអាងទឹកត្រពាំងថ្ម កាលណោះគេថាជាខ្សែក្រវ៉ាត់ ឲ្យជុំទៅដល់នោះណា ឲ្យឆ្ងាយណា ចាប់ពីស្ពានទីមួយ ទីពីរ ទីបី រហូត

ដល់ហួសព្រៃកូនក្មេងទៀតណា ខ្ញុំទៅនៅនោះម៉ាយប់សុទ្ធតែដុប ទៅមុនដំបូងចឹងមានជ្រូក មានអីចឹងមិនសឹងហ៊ានចេញពីរោង អាព្រៃកូនក្មេងនោះ ពួងឯងចាំស៊ើបទៅដឹងហើយ មុន ដំបូងមិនដូចសម័យសព្វទេ សម័យដែលខ្ញុំលើកនោះមានជ្រូកមានអីនោះ ខ្លាចមិនហ៊ាន ចេញទេ ។

ដារ៉ា : ជ្រូកព្រៃ?

បណ្ឌិត : ចាំ ជ្រូកព្រៃ ខ្ញុំមិនហ៊ានចេញទេ សឹងដុះបទដើងហៅគ្នាចង់ម៉ាភូមិ កុំក្នុងរោងឡើងរញ៉ាំ ពេលយប់ឡើងក្នុងរោងប្រុសម៉ារយស្រីម៉ារយទៅឯព្រៃហ្នឹងណា ប្រុងឲ្យលើកអាក្រវ៉ាត់ ណាទៀតហ្នឹង មើលទៅមិនកើតឲ្យពួកខ្ញុំត្រឡប់មកវិញទៅ អត់ទាន់លើកអាណោះទេណា លើកបានតិចទៅ ឲ្យទៅមើលព្រៃកូនខ្មែង សុទ្ធតែខ្លាចពួកខ្ញុំមកវិញហ្នឹង តាវ៉ាល់ឲ្យដក ចេញមកម្នាក់ឲ្យលើករួចហើយទៅ មកលើកអាទំនប់ស្ពានទីមួយ ឲ្យហើយចង់ទៅមើល អាដីក្នុងសុទ្ធតែព្រៃជ្រូក មិនដូចសព្វថ្ងៃទេដែលស្រឡះ ដែលពួកខ្ញុំទៅលើកហ្នុងស្តុកអួញ តំបន់អាពតនៅ ។

ដារ៉ា : ចុះ មីងលើកកន្លែងត្រពាំងថ្មហ្នឹងរួចរាល់?

បណ្ឌិត : រួច ។

ដារ៉ា : រួចចឹងមានគេមកសម្ពោធអីចឹងដែរ?

បណ្ឌិត : គេឆ្លង ជប់លាង គ្មានអ្នកណាមកសម្ពោធទេ គេហៅតែអ្នកធំមកជុំធ្វើអីហូបចឹងទៅណា បានឆ្ងាញ់ម៉ាពេលដូចថា គ្មានឆ្ងាញ់អីណាស់ណាទេ នំកូចាក់ម៉ាចង្កេចឹងទៅ យើងធ្វើត្រឹម តែហូបម៉ាពេលហ្នឹងទៅ បែជាស្អែកឡើងទៅយើងក៏ទៅធ្វើអីផ្សេងទៀតទៅ ។

ដារ៉ា : មានអ្នកធំណាមកចូលរួមឆ្លងទេ?

បណ្ឌិត : មានតែឈ្មោះអ្នកធំប៉ុន្មាននៅតំបន់ ៥ ហ្នឹង តាវ៉ាល់ តាមោង តាហឹង្ស ។

ដារ៉ា : អត់មានមេដឹកនាំមកពីមជ្ឈិមអីមកទេ?

បណ្ឌិត : ទេ ក្នុងតំបន់ ៥ ហ្នឹង មានតែពួកគាត់ហ្នឹង

ប្រុញ : តាហឹង្ស គាត់ធ្វើអីគេ?

បណ្ឌិត : តាហឹង្ស ប្រធានគណៈតំបន់ ។

ប្រុញ : ចុះ តាវ៉ាល់វិញ?

បណ្ឌិត : ខាងចល័តរួម អាហ្នឹងដូចថា ប្រធានក្តាប់ក្នុងម៉ាស្រុកមានប៉ុន្មានទាំងអស់គាត់ ក្តាប់រួមទាំង អស់ មានតាមជាន់តាមថ្នាក់គេ ។

អ្នកភូមិ ៖ គាត់ជាប្រធានទទួលខុសត្រូវខាងលើកទំនប់ទេ ។

បណ្ដែត ៖ តាវ៉ាល់ ជាប្រធានទទួលខុសត្រូវលើកទំនប់ទេ ។

អ្នកភូមិ ៖ អាទំនប់សំបូរស្រូវនោះ ទំនាលសព្វថ្ងៃ គេហៅថាទំនប់តាវ៉ាល់ ប្រចាំការមើលខុសត្រូវម៉ាតំបន់ ។

បណ្ដែត ៖ អស់ហើយ ។

ដារ៉ា ៖ ចុះ មីងមកដល់កន្លែងពេទ្យហ្នឹង មីងរត់មកភូមិ?

បណ្ដែត ៖ មកភូមិ ។

ដារ៉ា ៖ ដែលមីងថាធ្វើសំបុត្រក្លែងក្លាយ?

បណ្ដែត ៖ ចាំ រត់មកភូមិ ចុះបើគេចាប់មេកើយអស់ហើយ ក៏នូវខ្លាចសឹងងាប់ហើយគេចាប់វ៉ៃងាប់ទាំងអស់ ខ្ញុំខ្លាចរត់មកដល់តាប៉ែន ពេលនោះគេចាប់បង លុយ ធ្វើពេទ្យនៅកន្លែងតំបន់ចាប់គាត់ទៅនៅសល់តែប្រពន្ធទេ ដល់ប្រពន្ធនៅណោះឡើងជ្រួលច្របល់អស់ បិទទ្វារឡើងជិតខ្លាចគេមកចាប់ ខ្ញុំក៏រត់កាត់ម៉ាវាលនេះមក ដើរមកបាក្ដាមតិច បានខ្មៅដៃបន្តិច នៅសល់កន្លែងពេទ្យបានក្ដាមស៊ីដើរផ្លូវនោះឯង ខំគេថាឯងនោះរត់ ពេលឃើញឡានតាស៊្មីនៅនិរតីហ្នឹង ខ្ញុំចុះមុជទឹកត្រឹមមក ខ្លាចគេស្គាល់ ពេលដែលឡើងផុតមកបាន ខ្ញុំដើរកាត់ឡើងមកណោះផុតមកបានស្ងួតខ្លួនហើយ ខ្ញុំដកក្រដាស់ពីកាបូប ខ្ញុំបានសរសេរបើកផ្លូវមក ដើរកាត់ភ្នំជញ្ជាំងទៅភូមិតាប៉ែន ប៉ះឈ្លបកាក់តាមផ្លូវរកសំបុត្រខទ្មេសនាម ខ្ញុំថាមានកាពិតខ្ញុំធ្វើខ្លួន បើគេសើររើមែនទែនគ្មានបានរស់ទេ វាមិនសូវដូចថា វាក៏ឆែក ខ្ញុំក៏ហុចទៅ វាក៏មើលដាច់មិនដាច់ ខ្ញុំមិនដឹងទេ ខ្ញុំសរសេរប្រហែលប៉ុណ្ណេះក្រដាស់ខ្ញុំខ្លី សរសេររួចថាសូមឲ្យបងដែលនៅក្ដាប់រួមនៅសហករណ៍ឲ្យទទួលឈ្មោះ ឡុត បណ្ដែត នេះហូបបាយហូបទឹកផង ព្រោះអីគាត់សុំច្បាប់ពី បងលុយនេះ មកមើលម៉ែឪគាត់មិនស្រួល គាត់ហើមគាត់ហត់ ចេះថាទៅ... គាត់លើកអាសំបុត្រខ្ញុំមើលទៅ គាត់ឲ្យនៅខ្ញុំអររអួយអរ ខ្ញុំដេកតែភ័យ ។

ដារ៉ា ៖ ពូហ្នឹងយកសំបុត្រឲ្យប្រធានភូមិមីងឯងដែរ?

បណ្ដែត ៖ វាយកទៅឲ្យខ្លួនវា វាកាក់ផ្លូវចូលក្នុងភូមិ កាក់យកសំបុត្រពេលយកទៅ យកឲ្យប្រធានសហករណ៍ ប្រធានសហករណ៍ចេះបើកមើលទៅឃើញឈ្មោះឪពុកឈ្មោះនេះ ឈ្មោះនោះទៅ ខ្ញុំក៏ទៅពុកខ្ញុំទៅ ឲ្យបាយឲ្យអីហូបបើមិនចឹងគេមិនឲ្យបាយហូបហើយក៏មិនឲ្យយើងនៅទៀត ។

ដារ៉ា ៖ ប្រធានសហករណ៍ឈ្មោះអីមីង?

បណ្ឌិត ៖ ឈ្មោះតាស៊ីម សព្វថ្ងៃរស់នៅភ្នំឆ័ត្រលីគេនិយាយ ហើយគាត់ក៏ឲ្យនៅជាមួយម៉ែខ្ញុំក៏វល់វេកទៅ ។

ដារ៉ា ៖ ក្នុងភូមិជាមួយឪពុកម្ដាយមីងក្នុងភូមិតាប៉ែនហ្នឹង?

បណ្ឌិត ៖ ចា៎

ដារ៉ា ៖ ចឹងមកធ្វើការអីវិញក្នុងភូមិនេះ?

បណ្ឌិត ៖ មកដល់ភូមិនេះ ប្អូនខ្ញុំដែលនៅនោះដឹងថាខ្ញុំធ្វើពេទ្យនេះ គាត់ក៏ដូចខុះពេទ្យផង ធ្វើពេទ្យម្ដងទៀត គេឲ្យធ្វើប្រធានពេទ្យសហករណ៍ ខ្ញុំក៏ធ្វើ ពេលដែលឆែកអ្នកជម្ងឺរួចសព្វអស់ហើយ ខ្ញុំក៏ទៅតាមព្យាបាលអ្នកដកសំណាបដកអី ក៏លឺវិទ្យុគេផ្សាយយួនមកដល់តាណាតាណីហើយ ម្ដងណោះខ្ញុំក៏ភ័យ ម៉ែខ្ញុំក៏ទៅប្រូតនៅ ឯរនាម ខ្ញុំយោងថាទៅតាណាតាណីហើយខ្ញុំក៏បែកភ្លាម គាត់ក៏ដេញចាប់ខ្ញុំឲ្យទៅតាម គាត់ណា ។

ដារ៉ា ៖ អ្នកណាគេ?

បណ្ឌិត ៖ តាស៊ីម ឲ្យទៅតាមទ័ពព្រោះអីអត់មានអ្នកព្យាបាលមានតែខ្ញុំទេចេះណា គាត់ឲ្យខ្ញុំទៅតាមគាត់ណា តាមចាប់ដល់ឈូកពូនណា ខ្ញុំក៏ដេកពួនឡាឃឺអស់បីពេទ្យ ប្អូនខ្ញុំគាត់នៅធ្វើការនោះ នៅកន្លែងហ្នឹងបីនាក់ ខ្ញុំរត់ឡើងពុកម៉ែខ្ញុំតាមចាប់ខ្ញុំតើ ត្រូវយកមីដែតនេះឲ្យបានទៅតាមអ្នកស្រុក បើមិនទៅតាមអ្នកស្រុក បើខ្ញុំរត់ទៅ អ្នកស្រុកឈឺតាមដុប តាមព្រៃ អត់មានអ្នកណាចាក់ថ្នាំឲ្យទេ ត្រូវតែយកខ្ញុំឲ្យបានយកខ្ញុំមិនបានខ្ញុំពួន ខ្ញុំចូលទៅក្នុងជញ្ជ្រាំងបានពួន វាដើរជាន់ជញ្ជ្រាំងនោះឡើងអស់ វាដើររកកកាយភ្លឺឡើង ដល់តាមរកខ្ញុំមិនឃើញតាមផ្ទះចាស់ខ្ញុំនេះ បានពុកខ្ញុំនៅនេះ គាត់បានសួរពុក ពុកខ្ញុំមិននៅ មិនឃើញទេ វានៅឯវាលនោះឯង តាមយកខ្ញុំមិនបានទេខ្ញុំរត់ពួនសកតាមចំបើងទៅបានផុត កុំអីហ្នឹងខ្ញុំមិនបាននៅទេម្ល៉េះកុំអី ចាប់យកទៅបាត់ សន្តិភាពថាយួនមកដល់រហាលហើយ អីហើយតើក៏បែកអឺថារត់យកហើយតើ ម៉ែខ្ញុំទៅយកនៅបៀតម្រ៉ោច ខ្ញុំចេះតែរត់ទៅតាមគេទៅណា ថាយួនមកដល់ហើយណា ម៉ែខ្ញុំតាមយកមកផ្ទះវិញ ហើយក៏ចប់ត្រឹមនោះឯង ។

ប្រុញ ៖ មីងកាលហ្នុងអ្នកណាគណៈភូមិភាគ?

បណ្ឌិត ៖ គណៈភូមិនេះ

ប្រុញ ៖ អត់ទេ គណៈភូមិភាគ?

បណ្ឌិត ៖ គ្មានណាទេ មិនស្គាល់ទេ ដូចថាឆ្ងាយភូមិភាគមិនតិចទេណា ណាមិនស្គាល់យើងមិនដឹង យើងស្គាល់តាណាស្គាល់ ។

ដារ៉ា ៖ ចុះ រត់មកដល់ភូមិវិញ មកជួបជុំឪពុកម្តាយមីង គាត់មានរៀបរាប់ពីការងាររបស់គាត់ នៅក្នុងភូមិហ្នឹងធ្វើអីៗទេ?

បណ្ឌិត ៖ ម៉ែខ្ញុំ

ដារ៉ា ៖ បាទ

បណ្ឌិត ៖ គាត់ធ្វើនៅសម័យអាពត កាប់ចំការដាំដំឡូង ពុកខ្ញុំធ្វើការនៅសន្តមកិច្ចទៅ ខាងពុកខ្ញុំធ្វើគ្រូ ដុំគ្រូអីចឹងទៅណា បងប្អូនខ្ញុំធ្វើទាំងអស់ឯង កាប់ព្រៃ ធ្វើចំការ បងខ្ញុំមិញនេះឯង ពោះធំ កាប់កន្ទ្រានខែត្រធ្វើដីធ្វើអីទៅណា ។

ដារ៉ា ៖ មីងមានចាំឈ្មោះអ្នកណាខ្លះជាកូនក្រុមមីងទេ?

បណ្ឌិត ៖ បែកយូរហើយ

ដារ៉ា ៖ ឥឡូវហ្នឹងឲ្យតែចាំឈ្មោះមិនគិតថាស្លាប់រឺរស់ទេ?

បណ្ឌិត ៖ ស្គាល់មុខហើយស្គាល់ឈ្មោះទៀត ឈ្មោះតាលន់ ពូផល នៅភ្នំស្រុក លឿង ដាន ចាំវាមិនអស់ទេ នៅជាមួយគ្នា ។

ដារ៉ា ៖ លឿង ដាន នៅក្នុងភូមិនេះដែរ?

បណ្ឌិត ៖ ចា៎

ដារ៉ា ៖ គាត់រស់នៅដល់សព្វថ្ងៃនេះដែរ?

បណ្ឌិត ៖ គាត់រស់នៅនេះសព្វថ្ងៃ

ដារ៉ា ៖ ពូលឿងហ្នឹង

បណ្ឌិត ៖ ទៅថៃអស់ហើយ

ដារ៉ា ៖ ដានក៏នៅហ្នឹងដែរ ជាកូនកងមីងដែរ អាចមានចាំអ្នកនៅភ្នំពេញ អ្នកមកពីឆ្ងាយចូលមក?

បណ្ឌិត ៖ ហ៊ួ អ្នកភ្នំពេញ ឥឡូវមិនចាំឈ្មោះចាំតែមុខ ប្រុសៗអីក៏ដោយ សព្វថ្ងៃខ្ញុំភ្លេចឈ្មោះ អស់ហើយ ស្គាល់តែមុខ មុខឡើងចាស់រៀងៗខ្លួន ចាំតែម្នាក់គត់ឈ្មោះបងវ៉ាន់នៅវាល កប៉ាល់ហោះ នៅភ្នំពេញ ចាំគាត់ម្នាក់ ។

ដារ៉ា ៖ គាត់នៅរស់ដល់ចុងក្រោយដែរ?

បណ្ឌិត ៖ រស់ដល់ពេលបែកគ្នា ព្រោះខ្ញុំដឹងថា គាត់នៅវាលបែកចាន ខ្ញុំមិនដែលស្គាល់ផងភ្នំពេញ តែបាត់ដំបងមិនដែលស្គាល់ផង ។

ដារ៉ា ៖ មើងមានចាំអ្នកណាទៀតទេ មើងរកនឹកមើល?

បណ្ឌិត ៖ ច្រើនណាស់អ្នកទៅ ក្មួយអើយ ស្គាល់តែភ្លេចឈ្មោះវា វាទៅថៃហើយ សាគីទៅថៃហើយ ច្រើនគ្នាណាស់ក្មួយអ្នកថ្មីច្រើនជាងអ្នកចាស់ អ្នកថ្មីខ្ញុំអត់ចាំឈ្មោះទេ អ្នកចាស់គ្រាន់លាយតាមកងជម្រុះគ្នា មិនដាក់អ្នកចាស់ទាំងអស់ផងទេណា ដូចថាប្រជាជន ចាស់និងប្រជាជនថ្មីគេលាយចូលគ្នា មិនឲ្យនៅជុំគ្នាទេណា ដូចថាក្នុងម៉ាកងមានប្រជាជន ចាស់ដប់នាក់និងប្រជាជនថ្មីមកពីភូមិចម្រុះចូលគ្នា មកពីភូមិយើងខ្លះ មកពីភូមិគេខ្លះ ខ្ញុំទៅពីនេះតែម្នាក់ឯងទេ ។

ប្រុញ ៖ សម័យនោះមានវៀតណាធ្វើការអីជាមួយដែរ?

បណ្ឌិត ៖ អត់ទេ បើមានវៀតណាមងាប់អស់ អត់រស់ទេរកតែយួន សម័យអាពតឲ្យដឹងថាមានប្រវត្តិយួនយកទៅវ៉ៃចោល ឲ្យតែឈ្មោះយួនយកទៅវ៉ៃចោល មិនត្រឹមថាតែយួនទេឲ្យតែយើងធ្វើការខុស រៀនចេះ ជាទាហាន និស្សិតត្រូវតែងាប់ ទោះបីអ្នកចេះក៏គេមិនដែលដាក់ថាកូនអ្នកក្រ សួរថាចេះអីមិនដែលចេះអីទេ ត្រូវថាចេះបានរស់ បើយើងចេះយើងធ្វើជាចេះយើងមិនរស់ទេ បើយើងជានិស្សិតចេះលាក់បានរស់មកដល់សព្វថ្ងៃ បានយើងថាអ្នកចេះ បើយើងកូនអស់លោកចេះ យើងកុំថាទៅ ថាកូនអ្នកស្រែចំការទៅ អាចនៅក្នុងក្រុមយើងមានអ្នកណាស្គាល់យើងទៀតណា យើងកុំចេញស្តីថា កូនអ្នកនេះកូនអ្នកនោះ ។

ដារ៉ា ៖ គេមើលសាច់ឈាមអីដឹងទេ?

បណ្ឌិត ៖ កាលសម័យនោះ ពូអើយថ្ងៃវាល់ៗល្ងាចវាគ្មានសអីវាស្វាំងរៀងៗតែខ្លួន វានឿយនោះ ។

ដារ៉ា ៖ ទេ ពេលមកដំបូងនោះមីង?

បណ្ឌិត ៖ វ៉ៃតែដំបូងទេ ដល់យូរៗទៅវាខ្មៅអស់ឡុំ ចេះតែស៊ើបមកពីតាមភូមិ ស៊ើបពីភូមិមកចឹងណា វាភយ វាសារប្រវត្តិយើងណា កូននៅណា ពេលវ៉ៃនៅភូមិនេះរួច កូនប៉ុន្មាននៅណា នៅចល័តចាប់យកនៅចល័តនោះឯង អាហ្នឹងគេថាស្រាវជ្រាវប្រវត្តិ ចាប់យកនោះឯង យើងនេះអត់ដឹងអីទេ កូននោះមិនដឹងអីមានប្រវត្តិ តែយើងដឹងថា យើងកូនអ្នកធំហើយនៅឯផ្ទះមានរឿងរ៉ាវអីយើងអត់ដឹងទេ ស្រាវជ្រាវប្រវត្តិចេះឯង មិនអាចក្នុងកងទៅធ្វើអី ធ្វើអីក្នុងនាមយើងដែលខុសសីលធម៌នៅកងចល័ត បើយើង ការពារខ្លួនយើងបានក៏មិនអាចងាប់ដែរ បើយើងមិនការពារខ្លួនយើងបានមានតែងាប់ បើយើងធ្វេសប្រហែសចេះហើយ បើយើងប្រាប់ថាកូនអ្នកធំ កុំប្រាប់ពីនេះបាន ពីយើងរស់នៅពីក្នុង

ចេញចល័ត កុំឲ្យប្រាប់ពីម៉ែឪឲ្យបាន បើប្រាប់ពីម៉ែឪបានកូនប៉ុន្មាន វាមានក្នុងបញ្ជីស្រេចទៅហើយ ឈ្មោះនេះឈ្មោះនោះ វាស្រាវជ្រាវបាត់ បានទៅចាប់ នៅកន្លែងយោធាជួយចាប់ ។

ដារ៉ា : ចឹង ពួកយោធាចាប់?

បណ្ឌិត : ចាំ ចុះមេគេឲ្យចាប់ ស្រាវជ្រាវពីនេះទៅបានគេចាប់ បានគេថាមិនដឹងពីផ្ទះពីភូមិទៅយើងមិនអាច ខ្លាចតែកងចល័តនេះមិនអាច យើងការពារតែការខុសសីលធម៌ទៅបានហើយ ខំធ្វើការទៅ កុំនិយាយអីឲ្យខុសរឿងការងារគេ ពីនេះពីនោះអីមិនបាច់និយាយ យើងនិយាយពីរឿងរែកដីរែកអីប៉ុណ្ណោះបានហើយ គេថាឲ្យដាំដើមគនៅឲ្យស្ងៀមចុះត្រូវ ការចេះដេកក្នុងអង្រឹង រវល់តែរែកដីប៉ុណ្ណោះអាចវារស់ហើយ ។

ប្រុញ : អ្នកខុសសីលធម៌ភាគច្រើនគេយកទៅអប់រំ រឺ សម្លាប់ចោល?

បណ្ឌិត : អប់រំយើងម្តង គេតាមដានយើងណា តែយើងហ្នឹងថាគេមិនតាមតានយើង គេតាមដានយើងណា បើយើងខុសហើយណា គេដេញទាំងយើងទៀត ។

ដារ៉ា : សីលធម៌ហ្នឹងសំដៅលើអីខ្លះ?

បណ្ឌិត : សីលធម៌ហ្នឹងសំដៅលើការស្រឡាញ់គ្នា កាលសម័យវាថា ស្រលាញ់គ្នា វាថាខុសសីលធម៌រវាងស្រីនិងប្រុស ។

ដារ៉ា : ចង់ និយាយពីសកម្មភាពអីខ្លះ?

បណ្ឌិត : ស្រលាញ់គ្នា ទៅជួបគ្នា ស្នេហាដែលទៅជួបគ្នាហ្នឹងណា គេឃើញមាត់មនុស្សដែលស្គាត់ណាពូ ឃើញពូឯងស្រលាញ់ម្នាក់នោះ អ្ហូ មីនេះនិងអានោះណា ដល់គេតាមដានយូរណាស់យោធាណាហ្នឹង ដល់យប់ឡើងលូននៅបាតគ្រុបាញ់គ្នាចេះឯង រោងផ្ទះប៉ុណ្ណោះវាលូនឡើងកប់ ខ្លាចយើងនិយាយអី ល្ងាចឡើងយើងរែករួចយើងដេកទៅ ។

ដារ៉ា : ចុះ វាអត់ដេកទេចុះ?

បណ្ឌិត : វាដេកមិនដេកខ្ញុំអត់ដឹងដែរ ហើយយប់ឡើងរានខ្ពស់ប៉ុណ្ណោះពូឯងដេកទៅ ដេកឲ្យស្ងាត់ជ្រៀបទៅកុំឲ្យនិយាយថា អ្ហូយ ហងអើយស៊ីមិនឆ្អែតទេ ឯងមើលងាយបដិវត្ត វាប្រហារគេ ថាចុះក៏មិនថាដែរណា មិនត្រូវការឲ្យនិយាយ ស៊ីមិនឆ្អែតក៏ស្ងៀមទៅ ស៊ីឆ្អែតក៏ដោយស៊ីមិនឆ្អែតក៏ដោយនៅឲ្យស្ងៀមទៅ មិនបាចនិយាយថាអីទេ ធ្វើការគិតតែពីធ្វើទៅព្រឹកឡើងទៅធ្វើការទៅ ល្ងាចក៏រែកទៅ ខំរែកទៅ កុំនិយាយគាពិចគាពាសមិនបានទេចេញតែពីមាត់ខ្លួនឯងហ្នឹងខ្លាចសឹងងាប់ ខ្ញុំទៅពីស្រុកព្រះនេត្រព្រះប្រាំនាក់ចូលកង ទៅពី

នេះណា ទៅបែកគ្នាធ្វើប្រធានក្តាប់រួមរៀងៗខ្លួនទៅបែកគ្នាអស់ មានស្រុកពីរជញ្ជូនជម្រុកមកជំនួសយើង ទៅពីនេះមាន ខ្ញុំ លឿង ផាន អ្នកណាៗទៀតនៅភូមិនេះឯង ច្រើនតែភូមិប៉ោយសំរោង ប៉ោយអីទៅ ច្រើនមានចម្រុះគ្នាណា ទៅដល់ណោះគ្មាន នៅជុំគ្នាទាំងប្រាំទេ ខ្ញុំក៏ទៅខាងនោះទៅចម្រុះគ្នាលាយគ្នាវល់តែហ្នឹង ភូមិគេភូមិឯង ពីភ្នំស្រុកអីទៅពីប៉ោយសំរោង ប៉ោយព្រីងលាយគ្នាទៅ នៅម្តុំគ្នាយើងបេះអត់ទេ ខ្ញុំតែម្នាក់ខ្ញុំជាមួយអ្នកថ្មីអ្នកចាស់ ដល់ទៅនៅជាមួយគ្នាចឹងទៅដូចបងប្អូនចឹង ឈឺក៏មើលគ្នា ម្នាក់ម្តងទៅកោសគ្នាម្នាក់ម្តង បើឈឺអាចកោសបានទៅមើលគ្នាទៅ បើថាមិនអានមើល មិនជាទៅពេទ្យទៅ ។

ដារ៉ា ៖ ចឹង ពួកខ្ញុំដូចជាអត់មានអីសួរមីងទៀតទេ អស់ប៉ុណ្ណឹងហើយណាមីង ខ្ញុំអរគុណមីងច្រើនដែលផ្តល់បទសម្ភាសន៍ ។

បណ្ដែត ៖ ចា៎

ដារ៉ា ៖ បាទ

«ចប់»